MINISTRY OF PUBLIC WORKS AND TRANSPORT

General Directorate of Techniques
Road Infrastructure Department

# វិធីសាស្ត្រជួសជុលស្ពាន







February 2018

# មាតិកា


ជំពូកទី 1 ការណែនាំ

**1.1** គោលបំណងនៃការត្រួតពិនិត្យស្ពាន ---------------------------------------------------- 1 - 1

**1.2** ដំណើរការនៃការថែទាំ ------------------------------------------------------------------ 1 - 4

**1.3** សទ្ធានុក្រម ----------------------------------------------------------------------------- 1 - 5

**1.3.1** ប្រភេទស្ពាន ------------------------------------------------------------------------- 1 - 7

**1.3.2** រចនាសម្ព័ន្ធមូលដ្ឋានរបស់ស្ពាន ---------------------------------------------------- 1 - 10

**1.3.3** សទ្ធានុក្រមស្ពាន------------------------------------------------------------------- 1 - 12

ជំពូកទី 2 ការរៀបចំសម្រាប់តំហែទាំស្ពាន

**2.1** គម្រោងសង្ខេប ------------------------------------------------------------------------ 2 - 1

**2.2** កាលវិភាគ --------------------------------------------------------------------------- 2 - 3

**2.3** ដែនសមត្ថកិច្ច ----------------------------------------------------------------------- 2 - 4

**2.3.1** ការត្រួតពិនិត្យស្ពាន ------------------------------------------------------------- 2 - 4

**2.3.2** ការកត់ត្រាអំពីការត្រួតពិនិត្យស្ពាន --------------------------------------------- 2 - 11

**2.3.3**សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលអំពីការត្រួតពិនិត្យស្ពាន------------------------ 2 - 13

## ជំពូកទី 3 សុវត្ថិភាព និងការងារថែទាំ


3.1 ការរក្សាសុវត្ថិភាពសម្រាប់ការងារជួសជុល -------------------------------------------------- 3 - 1

3.1.1 ការណែនាំពីការងារសុវត្ថិភាព ---------------------------------------------------------------- 3 - 1

3.1.2 ការបញ្ជាក់មុនចាប់ផ្តើមការងារជួសជុល ---------------------------------------------------- 3 - 5

3.1.3 ការបញ្ជាក់ក្នុងអំឡុងពេលអនុវត្តការងារជួសជុល --------------------------------- 3 - 8

3.2 ការថែទាំប្រចាំ ------------------------------------------------------------------------------------------ 3 - 13

3.2.1 គោលបំណងនៃការថែទាំប្រចាំ -------------------------------------------------------------- 3 - 13

3.2.2 ការអនុវត្តលក្ខណៈវិនិច្ឆ័យ -------------------------------------------------------------------- 3 - 14

3.2.3 លំដាប់លំដោយការងារ --------------------------------------------------------------------------- 3 - 15


## ជំពូកទី 4 ចន្លោះសម្រាប់ធ្វើការថែទាំ និងចំណេះដឹងមូលដ្ឋានពីបេតុង


4.1 ចន្លោះសម្រាប់ធ្វើការថែទាំ ---------------------------------------------------------------------- 4 - 1

4.2 វត្ថុធាតុបេតុង ----------------------------------------------------------------------------------------- 4 - 7

4.2.1 សមាសធាតុនៃបេតុង ------------------------------------------------------------------------------ 4 - 7

4.2.2 គ្រួស ------------------------------------------------------------------------------------------------------ 4 - 8

4.2.3 ស៊ីម៉ង់ ---------------------------------------------------------------------------------------------------- 4 - 9

**4.3 ការខូចខាតបណ្តាលមកពីកំហុសសាងសង់** ---------------------------------------------- 4 - 10

**4.3.1 ការផ្លុះសុល និងប្រហោង** ---------------------------------------------------------------- 4 - 11

**4.3.2 ពងទឹក និង ស្នាមខ្យាច់** ---------------------------------------------------------------- 4 - 13

**4.3.3 ស្នាមប្រេះ** ---------------------------------------------------------------------------------- 4 - 14

**4.3.4 តំណត្រជាក់** ------------------------------------------------------------------------------- 4 - 16

**4.4 ការងារបេតុង** --------------------------------------------------------------------------------- 4 - 18

**4.4.1 តម្រូវការសម្រាប់វត្ថុធាតុបេតុងថ្មី** ----------------------------------------------------- 4 - 18

**4.4.2 ការរក្សាទុក** -------------------------------------------------------------------------------- 4 - 19

**4.4.3 ការងារបេតុង** ------------------------------------------------------------------------------ 4 - 20

**4.4.4 ការងារ និងការដាក់ឆ្អឹងដែក** ------------------------------------------------------------ 4 - 24

**4.5 ការសាកល្បងបញ្ជាក់ពីគុណភាពបេតុង** ----------------------------------------------------- 4 - 25

**4.5.1 ការសាកល្បងការធ្លាក់ចុះ** ------------------------------------------------------------------ 4 - 25

**4.5.2 ការសាកល្បងសមាសធាតុខ្យល់** ----------------------------------------------------------- 4 - 27

**4.5.3 ការសាកល្បងកម្លាំងសំពាធ** -------------------------------------------------------------- 4 - 29

**4.5.4 ការធ្វើតេស្តសរកអ៊ីយ៉ុងក្លរ** ---------------------------------------------------------------- 4 - 31

ជំពូកទី 5 ការជួសជូលរចនាសម្ព័ន្ធបេតុង


**5.1 ផែនការ ជួសជុលរចនាសម្ព័ន្ធបេតុង** -------------------- 5 - 1

**5.2 ករណីនៃការជួសជុលរចនាសម្ព័ន្ធបេតុង** -------------------- 5 - 3

**C-1 បេតុងមានស្នាមប្រេះ** -------------------- 5 - 3

**C-2 វិធីសាស្ត្រថែទាំស្ពានដោយប្រើ Carbon Fiber Cloth (CFC)** -------------------- 5 - 16

**C-3 សំនឹកនៃឆ្អឹងដែកក្នុងសរសរបេតុង** -------------------- 5 - 73

**C-4 ការខូចខាតលើទម្រសរសរបេតុង** -------------------- 5 - 75

**C-5 ប្រហោងក្នុងក្រចាប់តំណផ្នែកខាងក្រោម** -------------------- 5 - 79

**C-6 ការហៀរទឹកចេញពីក្រចាប់តំណផ្នែកខាងក្រោម** -------------------- 5 - 81

**C-7 ស្នាមប្រេះធ្វើឲ្យខូចខាតលើប្លង់សេ** -------------------- 5 - 84

**C-8 ការបាក់** -------------------- 5 - 88

**C-9 សំនឹកសរសៃដែកមេក្នុងរបាំងបេតុង** -------------------- 5 - 94

**C-10 ការខូចខាតរបាំងបេតុងដោយសារតែយានយន្តប៉ះទង្គិច** -------------------- 5 - 99

**C-11 ស្នាមប្រេះបណ្តោយក្នុងក្រចាប់តំណផ្នែកខាងក្រោមនៃឃ្នាប** PC -------------------- 5 - 104

**C-12 សរសរបេតុងទទួលរងខូចខាតដោយការប្រតិកម្មគ្រួសអាល់កាឡាំង**-------------------- 5 - 107

## ជំពូកទី 6 ការផ្ជួសជុលគ្រឿងបង្គុំពីដែក


**6.1 ការរៀបចំគម្រោងជួសជុលគ្រឿងបង្គុំពីដែក** ------------------------------------------------ 6 - 1

**6.2 ករណីធ្វើការជួសជុលគ្រឿងបង្គុំស្ពានដែក** ------------------------------------------------ 6 - 2

**S-1 ការលេចទឹកធ្វើឲ្យធ្នឹមដែកសឹក** ------------------------------------------------ 6 - 2

**S-2 ស្នាមប្រេះនៅគន្លាក់តភ្ជាប់ទ្រនាប់ ធ្នឹមបញ្ឈររាងជាអក្សរ I** -------------------------- 6 - 6

**S-3 ស្នាមប្រេះអក្សរ Mនៅលើត្រចៀកបេតុង ឬក៏ត្រចៀកដែកនៅជុំវិញធ្នឹមដែកជំនួយ**

**អក្សរ I** ------------------------------------------------ 6 - 11

**S-4 ការប្រេះស្រាំនៅធ្នឹម ‘haunch girder’** ------------------------------------------------ 6 - 15

**S-5 សំណឹកសរសៃស្ពានដែក** ------------------------------------------------ 6 - 20


## ជំពូកទី 7 ការរៀបចំគ្រឹះ ឬរចនាសម្ព័ន្ធផ្សេងៗ


**7.1 ករណីនៃការរៀបចំរចនាសម្ព័ន្ធស្ពានផ្សេងៗ** ------------------------------------------------ 7 - 1

**J-1 ភាពខូចខាតលើមុខដំណាពង្រីក** ------------------------------------------------ 7 - 1

**J-2 សំណឹកស្ពាន** ------------------------------------------------ 7 - 14

ឯកសារភ្ជាប់

បទដ្ឋានសំរាប់ការងារជួសជុលស្ពាន

**លេខកូដ : 1-0001** ការជួសជុលបេតុងដែលមានស្នាមប្រេះ

**លេខកូដ : 1-0002** ការជួសជុលបេតុងដែលខូចខាត

**លេខកូដ : 1-0003** ឆ្អឹងដែកផ្ទៃបេតុង

**លេខកូដ : 1-0004** ឆ្អឹងដែកដោយបន្ទះដែក

**លេខកូដ : 2-0001** ការជួសជុលសំណឹកដែក

**លេខកូដ : 2-0002** ពង្រឹងគុណភាពដោយបន្ទះដែក

# ជំពូកទី1 ការណែនាំ

## 1.1 គោលបំណងនៃការត្រួតពិនិត្យស្ពាន

ប្រើប្រាស់ពាក្យប្រៀបធៀប បណ្តាញផ្លូវគឺសម្រាប់បម្រើដល់សកម្មភាពសេដ្ឋកិច្ចសង្គម ជាតិដូចជាការដឹកជញ្ជូន ការធ្វើដំនើរ និងការប្រាស្រ័យទាក់ទងផ្សេងៗ ដែលដូចជាបណ្តាញ សរសៃឈាមនៅក្នុងរាងកាយមនុស្ស (**Fig. 1.1.1**) ដើម្បីថែរក្សារាងកាយឲ្យមានសុខភាពល្អ មនុស្សត្រូវតែធ្វើការពិនិត្យស្ថានភាពរាងកាយជារៀងរាល់ថ្ងៃ ហើយត្រូវទទួលដំបូន្មានតំបូន្មានពីវេជ្ជ បណ្ឌិតឲ្យបានទៀងទាត់ ហើយក៏ត្រូវរក្សារាងកាយពួកគេឲ្យស្ថិតឲ្យមានសុខភាពល្អដែរ ហើយពេលខ្លះពួកគេអាចនឹងទទួលការព្យាបាល ឬក៏ការវះកាត់ដែរ។

ហេដ្ឋារចនាសម្ព័ន្ធផ្លូវក៏ដូចគ្នាដែរសម្រាប់ការដឹកជញ្ជូន។ ដូច្នេះ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ពិតជាសំខាន់ សម្រាប់សេដ្ឋកិច្ចប្រទេសកម្ពុជា។

ស្ពានគឺជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងហេដ្ឋារដនាសម្ព័ន្ធផ្លូវ។ ស្ពានដែលឆ្លងកាត់ទន្លេគឺជាសមាសធាតុ បណ្តាញផ្លូវមួយយ៉ាងសំខាន់ដែលចូលរួមយ៉ាងធំធេងក្នុងការអភិវឌ្ឍន៍ជាតិ និងជិវិតប្រចាំថ្ងៃរបស់មនុស្ស។ ការខូចខាត ឬក៏រលំបាត់បង់ស្ពានអាចបណ្តាលឲ្យមានហានិភ័យដល់អ្នកប្រើប្រាស់ផ្លូវ ហើយថែមទាំងមាន ឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ទូទាំងប្រទេសផងដែរ។ ជាងនេះទៅទៀត ការសាងសង់ស្ពានឡើងវិញត្រូវការថវិការ និងពេលវេលាដែលត្រូវគិតគូរយ៉ាងហ្មត់ចត់។ ជាក់ស្តែង ប្រទេសអេត្យូពីធ្លាប់មានបទពិសោធន៍ជាច្រើនដែល ទាក់ទងទៅនឹងការរលំស្ពាន និងបង្ករឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរបន្តជាច្រើនទសវត្សរ៍។



**Fig. 1.1.1** ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងសរសៃឈាម

អាយុកាលរចនាសម្ព័ន្ធគឺជារយៈពេលដែលរក្សាកម្រិតគុណភាពដែលវាត្រូវការ។ ហើយប្រវែង រយៈពេលអាស្រ័យទៅលើគម្រោងព្រាង គុណភាពសំណង់ ជាមួយឬក៏មិនជាមួយនឹងការ ជួសជុលឬក៏ការពង្រឹងគុណភាព។ ទោះបីជាការជួសជុលមិនត្រូវការថវិការ ត្រូវបានដាក់បញ្ចូលក្នុងអំឡុងពេលរៀបចំគម្រោងអាយុកាល ការជួសជុលទាមទារឲ្យប្រើរយៈពេលយូរ។ គុណភាពរចនាសម្ព័ន្ធត្រូវបានកាត់បន្ថយដោយសារអាយុកាលរបស់វា ក៏ប៉ុន្តែការអយុកាលរបស់អាចបន្ថែមបានដោយត្រូវធ្វើការជួសជុលឲ្យបានត្រឹមត្រូវ។ ដូច្នេះ ការជួសជុលពិតជាមានឥទ្ធិពលយ៉ាងធំនៅលើកម្រិតគុណភាពរចនាសម្ព័ន្ធ និងអាយុកាលរបស់វា។

វាពិតជាសំខាន់ក្នុងការពន្យារអាយុកាលដើម្បីធ្វើការត្រួតពិនិត្យដោយប្រើប្រព័ន្ធ អាស្រ័យលើប្រភេទរចនាសម្ព័ន្ធតួនាទីដែលបានគ្រោងទុក និងកម្រិតតម្រូវការគុណភាពដើម្បីស្វែងរកការខូចក្នុងដំណាក់កាលដំបូង ដើម្បីស្វែងរកមូលហេតុ ដើម្បីប៉ាន់ស្មានដំនើរការនៃការខូចដែលអាចកើតមាននៅពេលអនាគត និងដើម្បីជៀសវាងធ្វើការជួសជុល។ ការប្រមូលយកពត៌មានក្នុងពេលធ្វើការជួសជុលក៏ពិតជាចាំបាច់ដែរ។

‘**Fig. 1.1.2**’ បង្ហាញអំពីគោលគំនិតជៀសវាងការជួសជុល។ ជាទូទៅ ភាពរឹងមាំរចនាសម្ព័ន្ធមានការធ្លាក់ចុះពីមួយឆ្នាំទៅមួយឆ្នាំ ប៉ុន្តែគុណភាពរបស់អាចធ្វើការស្រោចស្រង់បានតាមរយៈការជួសជុល។ ប្រសិនបើស្ថានភាពបច្ចុប្បន្ន ហើយដំនើរការនៃការធ្លាក់ចុះគុណភាពអាចធ្វើការតាមដានបាន និងស្វែងរកក្នុងដំណាក់កាលដំបូងបាន ការជួសជុលអាចនឹងមានតិច។ យ៉ាងណាមិញ ប្រសិនបើការធ្លាក់ចុះគុណភាពមានការធ្វេសប្រហែសក្នុងការតាមដានរហូតឈានទៅដល់ស្ថានភាពធ្ងន់ធ្ងរ ការជួសជុលក្នុងស្ថានភាពធំពិតជាត្រូវការក្នុងការស្តារគុណភាពឡើងវិញ។ ដើម្បីកាត់បន្ថយបន្ទុកនៃការជួសជុលនាពេលអនាគតដើម្បីបន្ថយការចំនាយក្នុងការពន្យារអាយុកាលស្ពានការត្រួតពិនិត្យនិងការជួសជុលយូរៗម្តង និងជារៀងរាល់ពេលពិតជាសំខាន់។

គោលបំណងនៃ <u>សៀវភៅណែនាំនេះ</u> គឺចង់បកស្រាយ និងណែនាំអំពីស្តង់ដារនៃការថែរក្សា <u>ដើម្បីការពារកុំឲ្យមានការខូចខាត</u>ដែលភាគច្រើនត្រូវបានរកឃើញនៅលើស្ពាន ហើយការថែ រក្សាដោយក្រសួងសាធារណការ និងដឹកជញ្ជូន និងនាយកដ្ឋានសាធារណការ និងដឹកជញ្ជូន។




**Fig. 1.1.2** គោលគំនិតពីការជៀសវាងការជួសជុល

## 1.2 ដំណើរការនៃការថែទាំ

ការថែទាំរចនាសម្ព័ន្ធគឺជាសកម្មភាពតគ្នាដែលមាននូវការត្រួតពិនិត្យ ការកំណត់ពីមូលហេតុដែលបណ្តាលឲ្យខូចខាត ការកំណត់ទៅលើការធ្លាក់ចុះខ្សោយ វាយតម្លៃទៅលើគុណភាព កំណត់ទៅលើ ការជួសជុលដែលចាំបាច់ ការអនុវត្តការងារ និងការកត់ត្រាលើការថែទាំ។ ការថែទាំត្រូវធ្វើឲ្យបានត្រឹមត្រូវ ដោយយោងទៅតាមគម្រោងថែទាំ ដើម្បីធានាលើគុណភាពរចនាសម្ព័ន្ធ តាមរយៈតម្រូវការសេវាកម្ម។




**Fig. 1.2.1 ដំណើរការ នៃការថែទាំស្ពាន**

## 1.3 សទ្ទានុក្រម

សមាសភាគស្ពានរួមមានប្លង់សេផ្ទៃស្ពាន(deck slab) រចនាសម្ព័ន្ធខាងលើ(superstructure) រចនាសម្ព័ន្ធខាងក្រោម (substructure) (សរសរស្ពាន ជន្ទល់ និងគ្រឹះ) និងផ្លូវតភ្ជាប់ដូចដែលបានបង្ហាញនៅក្នុង **Fig.1.3.1** និង **Fig.1.3.2**




**Fig.1.3.1 ស្ពានដៃមួយ**




**Fig.1.3.2 សទ្ទានុក្រមរចនាសម្ព័ន្ធស្ពាន**




**Photo 1.3.1 សទ្ទានុក្រមធ្នឹម**




**Photo 1.3.2 សទ្ទានុក្រមរចនាសម្ព័ន្ធខាងលើ នៅផ្ទៃខាងលើ (superstructure)**

### 1.3.1 ប្រភេទស្ពាន

រូបសណ្ឋានស្ពានរួមមាន២ផ្នែក៖ រចនាសម្ព័ន្ធខាងលើរួមមាន ផ្ទៃខាងលើ កំរាល/បាត និងធ្នឹម/រនូត ហើយរចនាសម្ព័ន្ធខាងក្រោម (substructure) ទ្រូរចនាសម្ព័ន្ធខាងលើ ។ ប្រភេទនៃរចនាសម្ព័ន្ធខាងលើ ត្រូវបានបែងចែកទៅតាមរូបធាតុ របៀបនៃការទ្រទ្រង់ និងសណ្ឋាននៃ រចនាសម្ព័ន្ធដូចខាងក្រោម៖

### (a) ការបែងចែករូបធាតុ៖

1) ស្ពានដែក៖ ស្ពានដែលបានធ្វើឡើងដោយដែកថែបភាគច្រើន

2) ស្ពានបេតុងអាម៉េ (RC)៖ ស្ពានដែលបានធ្វើឡើងដោយបេតុងអាម៉េ

3) ស្ពានបេតុងប្រ៉េកុងត្រាំង (PC)៖ ស្ពានដែលបានបង្កើតឡើងដោយទាញដែកមុនរួចទើបចាក់បេតុងចូល

### (b) ការបែងចែកជាសណ្ឋានរចនាសម្ព័ន្ធ

#### 1) ស្ពានធ្នឹម

លក្ខណៈមេកានិកនៃ ស្ពានធ្នឹមគឺជាធ្នឹមដែលប្រើប្រាស់សម្រាប់ការពារលំនឹង និងកម្លាំងទម្ងន់។ ដែកមានរាងជាអក្សរ I និងអក្សរ H ត្រូវបានគេប្រើភាគច្រើនសម្រាប់ស្ពានដែក ហើយត្រូវបានគេហៅវាថា "ស្ពានធ្នឹមបន្ទះ" **(Photo 1.3.1)**។ "សមាសធាតុធ្នឹមស្ពាន" គឺត្រូវបានគ្រោងឡើងជាប្លង់សេបេតុងអាម៉េ ហើយធ្នឹមជួយទប់ផ្ទៃងទាំងស្រុងនៃស្ពានសម្រាប់យានយន្តធ្វើដំណើរឆ្លងកាត់។ ស្ពានដែលមានរាងជាប្រអប់ ធ្នឹមស្ពានត្រូវបានគេហៅវាថា "ស្ពានធ្នឹមប្រអប់" **(Photo 1.3.3)**



**Photo 1.3.3 ស្ពានធ្នឹមប្រអប់ (Box girder bridge)**

#### 2) ស្ពានបេតុងប្លង់បង់សេ

ស្ពានបេតុងប្លង់សេត្រូវបានប្រើប្រាស់សម្រាប់ស្ពានមានប្រវែងខ្លី ដោយសារតែកន្លែងផ្លូវខូច មានសភាពកាន់តែធ្ងន់ធ្ងរដោយសារតែប្រវែងរបស់វា។ ម្យ៉ាងទៀត វាមានអត្ថប្រយោជន៍ ដោយសារតែរយៈពេលនៃការសាងសង់មានរយៈពេលខ្លី ហើយអាចសន្សំសំចៃទៅលើការងារ នៅការដ្ឋាន ដោយសារតែរចនាសម្ព័ន្ធ និងការងាររបស់វាមានភាពសមញ្ញ។



**Photo 1.3.4 ស្ពានបាតបេតុង**

### 3) ស្ពានដែក (Bailey bridge)

ស្ពានដែក គឺជាប្រភេទមានប្រហោងដែក ស្ពានខ្វែង។ ស្ពាននេះត្រូវបានបង្កើតឡើងដោយជនជាតិ អង់គ្លេស ក្នុងអំឡុងពេលសង្គ្រាមលោកលើកទី២ សម្រាប់ឲ្យទាហានធ្វើការឆ្លងកាត់ ហើយត្រូវបានប្រើប្រាស់យ៉ាងច្រើន ទាំងវិស្វករអង់គ្លេសនិងអាមេរិច។

ធ្នឹមដែកប្រភេទ "ប្រហោង" ផ្លូវធ្វើចរាចរណ៍ត្រូវបានទប់នៅចន្លោះធ្នឹម មេទាំងពីរ។ ធ្នឹមមេ ត្រូវបានបង្កើតឡើងដោយផ្នែក ផ្សេងៗដែលមានប្រវែង ៣ម ចងភ្ជាប់គ្នាពីចុង ម្ខាងដល់ចុងម្ខាងទៀត។



**Photo 1.3.5 ស្ពានដែក (Bailey bridge)**

### 4) ស្ពានខ្សែកាប (Cable stayed bridge)

ស្ពានខ្សែកាបតភ្ជាប់ធ្នឹមដោយខ្សែកាបដែលត្រូវបានរៀបចំពីចុងកំពូលនៃបង្គោលសសរស្ពាន។ កម្លាំងសង្កត់ទៅលើធ្នឹម និងកម្លាំង ទាញខ្សែកាបត្រូវមានភាពស្មើគ្នាទាំងសងខាង។ ស្ពានប្រភេទនេះអាចជួយសន្សំសំចៃ គន្លងស្ពានបានរហូតដល់ ៩០០ម។ សព្វថ្ងៃនេះ ចំងាយស្ពានត្រូវបានពន្យា ឆ្ងាយជាង ៨០០ម។ ដែកបញ្ឈរ ជាទូទៅត្រូវកែសម្រួលសម្រាប់កម្រាលតម្រៀបគ្នា។



**Photo 1.3.6 ស្ពានខ្សែកាប (ស្ពាន Tsubasa)**

### 5) ស្ពានដែកខ្វែង (Truss bridge)

ស្ពានខ្វែងមានគែមរចនាសម្ព័ន្ធ អមមកជាមួយគ្នា មានរងជាងត្រីកោណ ហើយតភ្ជាប់គ្នាដោយខ្ទៅ។ ស្ពានខ្វែងប្រើដែកខ្វែងជារចនាសម្ព័ន្ធមេ។ លក្ខណៈមេកានិចគឺជា គ្រោងដែកទប់ទម្ងន់ត្រូវមានចាត់ទុកថាមានឥទ្ធិពលតែលើការសង្កត់ ឬសម្ពាធនៃកម្លាំងអ័ក្សប៉ុណ្ណោះ។



**Photo 1.3.7 ស្ពានដែកខ្វែង (Truss bridge)**

### 6) ស្ពានកោង (Arch bridge)

រចនាសម្ព័ន្ធកំណោងទ្រផ្នែកទាំងសងខាងនៃធ្នឹម ឬក៏រនូតខ្វែងឲ្យតឹងមាំ។ ធ្នឹងកោងគឺជារចនាសម្ព័ន្ធ គោលសម្រាប់ទប់កម្លាំងសង្កត់ និងការបត់។ រចនាសម្ព័ន្ធស្ពានដែលត្រូវទប់កម្លាំងដេកត្រូវបាន គេហៅថា “ស្ពាន កោង”





**Photo 1.3.8 ស្ពានកោង (Arch bridge)**

## 1.3.2 រចនាសម្ព័ន្ធមូលដ្ឋានរបស់ស្ពាន

### (a) រចនាសម្ព័ន្ធខាងលើ និងខាងក្រោម

រូបសណ្ឋានស្ពានត្រូវបានបង្ហាញនៅក្នុងរូប **Fig. 1.3.3** រចនាសម្ព័ន្ធខាងលើ គឺជាផ្នែកមេនៃស្ពាន ដែលតភ្ជាប់ ដំបូល/ផ្ទៃលើផ្លូវ និងធ្នឹម/រនូត។ រចនាសម្ព័នខាងក្រោមទ្រទ្រង់រចនាសម្ព័ន្ធខាងលើ ហើយបញ្ជូនទម្ងន់ទៅ លើដី។ វាតភ្ជាប់ជន្ទល់សសរ និងគ្រឹះ។ ស្រទាប់បំនែកតូច ថ្មតូចៗសម្រាប់ធ្វើផ្លូវ(DBST) ឬក៏បេតុងផ្តល់ភាពរលូនដល់ការធ្វើដំណើរលើផ្ទៃខាងលើ។ (ផ្ទៃខាងលើដែលរងសំណឹក)




**Fig. 1.3.3 រូបសណ្ឋានស្ពាន**

### (b) ទ្រនាប់ (Bearing)

ជាទូទៅទ្រនាប់តភ្ជាប់ធ្នឹមស្ពាន និសសរស្ពាន។ ថាទ្រនាប់ត្រូវបានដាក់បញ្ឈរឲ្យនៅនឹងថ្កល់ ឬក៏ឲ្យស្ពានមានចលនា និងរើម្រាស់បានដោយ សារតែខ្យល់ និងរញ្ជួយផែនដី។



**Photo 1.3.9 ទ្រនាប់ (Bearing)**

### (c) បន្ទះដែក និងប្រព័ន្ធផ្នែកម្រាល

បន្ទះដែកគឺជាសមាសធាតុមួយនៅក្នុងរចនាសម្ព័នខាងលើដែលទប់ទម្ងន់យានយន្តដោយ ផ្ទាល់ ហើយបញ្ជូនទៅកាន់ធ្នឹមដោយផ្ទាល់ ឬក៏តាមរយៈប្រព័ន្ធផ្នែកម្រាល។ វារួមផ្សំដោយ ប្លង់សេបេតុងអាម៉េ ប្លង់សេបេតុងប្រ៉េកុងត្រាំង និងដែកបញ្ឈរប្លង់សេ។ ផ្លូវកៅស៊ូត្រូវបានអ៊ុតលើវា។




**Fig. 1.3.4 Bracing**

### (d) គ្រឿងទាមពង្រឹងចំហៀង និងគ្រឿងពង្រឹងលំនឹង

ធ្នឹមនីមួយៗត្រូវបានតភ្ជាប់ជាមួយនឹងរចនាសម្ព័ន្ធខ្វែង ដូចជាគ្រឿងទាមពង្រឹងចំហៀង ឲ្យឈរដោយផ្ទាល់ និងគ្រឿងពង្រឹងលំនឹងនៅតាមផ្នែក។ គ្រឿងទាមពង្រឹងចំហៀងទប់កម្លាំង ដែលបណ្តាលមកពីខ្យល់ និង រញ្ជួយដី ហើយគ្រឿងពង្រឹងលំនឹងគឺដើម្បីបញ្ចៀសការខូចខាតតាមផ្នែក។



**Photo 1.3.10 គ្រឿងបរិក្ខាបង្ហូរទឹក**

### (e) គ្រឿងបំពាក់ផ្លូវ

### 1) គ្រឿងបរិក្ខាបង្ហូរទឹក

ដើម្បីនាំទឹកភ្លៀងដែលនៅលើស្ពានឲ្យនៅតែហូរទៅបំពង់លូលើដី បំពង់ទុយោត្រូវដាក់ឲ្យបាន ត្រឹមត្រូវនៅផ្ទៃលើស្ពាន។ ទឹកភ្លៀងហូរពីបំពង់ ទុយោទៅលើដីតាមរយៈធ្នឹម និងសសរស្ពាន ជាមួយនឹងបំពង់បង្ហូរទឹក។

### 2) តន្លាក់ភ្ជាប់ (Expansion joint)

តំណរីករួមអាចឲ្យធ្នឹមបំលាស់ទីដោយសាតែមានការផ្លាស់ប្តូរអាកាសធាតុ និងរក្សាភាពស្មើលើផ្លូវ។ បន្ថែមពីនេះទៅទៀត វាមានមុខងារដូចជាបំពង់ប្រឡាយទឹកនាំទឹកភ្លៀង។ ជាទូទៅ ប្រភេទតំណត្រូវបានជ្រើស រើសទៅតាមបំលាស់ទីរបស់ធ្នឹម តំណងកៅស៊ូ និង ដែកដែលមានការប្រើប្រាស់ភាគច្រើន។



**Photo 1.3.11 តន្លាក់ភ្ជាប់ (Expansion joint)**

### 1.3.3 សន្ទានុក្រមស្ពាន

មានបញ្ជីពាក្យវិស្វកម្មដែលត្រូវបានប្រើនៅក្នុងសៀវភៅណែនាំនេះ និងអត្ថន័យ។ ( **_______** ៖ ពាក្យសំខាន់)

**ជន្ទល់** - កន្លែងទប់រចនាសម្ព័ន្ធខាងលើស្ពាន ហើយជាទូទៅមានមុខងារបន្ថែម ក្នុងការទប់ដីផ្លូវ ភ្ជាប់ស្ពាន **(Fig. 1.3.1)**

**ទំនប់ទប់ផ្លូវតភ្ជាប់** - ទំនប់ ឬការចាក់ដីបំពេញដើម្បីបង្កើតផ្លូវតភ្ជាប់ទៅជន្ទល់ស្ពាន **(Fig. 1.3.1)**

**ផ្លូវភ្ជាប់** - ផ្លូវក្បែរជន្ទល់ស្ពាន **(Fig. 1.3.1)**

**ជន្ទល់មាត់ច្រាំង** - ជន្ទល់ដែលដំឡើងពីលើមាត់ច្រាំងទន្លេ ពីលើកម្ពស់ទូទៅនៃទឹកទន្លេ។

**ទម្រកោង** - ផ្នែកសំខាន់នៃផ្នែកកោងដែលទប់ដី និងនៅពេលជួលជុលផ្លូវថ្នល់។

**ធ្នឹម** - ផ្នែកមួយនៃរចនាសម្ព័ន្ធរូមតូច ដូចជា ឃ្នាប ទ្រនង់ ធ្នឹមផ្នែកម្រាល ធ្នឹមខ្វែង (ចន្ទល់ជ្រែង) ធ្នឹមគែម ។ល។

**ទ្រនាប់** - ផ្នែកចន្លោះរចនាសម្ព័ន្ធលើ និងការរងបន្ទុកនៃសសរ ឬចន្ទល់។ ថាសទ្រនាប់ផ្ទេរ បន្ទុកពីរចនាសម្ព័ន្ធលើទៅរចនាសម្ព័ន្ធក្រោម ហើយអាចនឹងធ្វើចលនាបាន ឬនៅជាប់មួយកន្លែង អាស្រ័យទៅលើកម្រិតនៃចលនាដែលត្រូវបានអនុញ្ញាត។ **(Photo 1.3.9)**

**ប៊ូឡុងទ្រនាប់** - ប្រភេទនៃគ្រឿងភ្ជាប់តំណដែក ឬឈើ។

**ផ្ទើរទ្រនាប់** - ផ្នែកនៃចន្ទល់ស្ពានសម្រាប់ទ្ររចនាសម្ព័ន្ធលើ។

**គ្រឿងធ្នឹម៖** - មេធ្នឹមខាងលើ និងខាងក្រោមដែលលាតសន្ធឹងបណ្តោយគ្រោងដែស្នា។

**ឃ្នាបប្រអប់** - ធ្នឹមប្រហោងដែលមានរាងជាប្រអប់ **(Photo 1.3.3)**

**មេពង្រឹង** - ផ្នែកនៃស្ពានដែលជួយទប់កម្លាំងពីចំហៀង និងជួយឲ្យមាំ ដើម្បីកុំឲ្យប្រែប្រួលទ្រង់ ទ្រាយ ឧទា. មេខ្វែងចំហៀង និងទទឹងក្នុងគ្រោងដែស្នា និងស្ពានធ្នឹមដែក។

**ការប៉ោង** - ទីកន្លែងដែលកន្លែងរាបស្មើផ្លាស់ប្តូរទ្រង់ទ្រាយ និងកោង។

**កំណោង** - ការកោងឡើងបន្តិចក្នុងការសាងសង់ស្ពាន ដើម្បីទប់ទល់នឹងកម្លាំងប្លាតនៃទម្ងន់ងាប់។

**គ្រឿងបំពង់លូ** - ប្រភេទនៃគ្រឹះឥដ្ឋ ឬបេតុង ដែលសាងសង់ដូចជាបំពង់លូ។

**ខ្នល់** - ធ្នឹមដែលបានភ្ជាប់នៅជ្រុងម្ខាង ហើយម្ខាងទៀតអាចធ្វើចលនាបាន។



**សំណឹក**

**ការសង្កត់** - ការបង្ហាប់ចូលគ្នា។

**សំណឹក** - ការសឹករិចរិលនៃសម្ភារៈសំណង់ (ជាទូទៅ គ្រឿងដែក) ដោយសារប្រតិកម្មគីមី (អុកស៊ីតដែលមានស្ថេរភាពជាង)។

**ដែកស័ង្កសី** - បន្ទះដែកស្តើងដែលត្រូវបានពត់ឲ្យមានភាពរឹងមាំ។

**ធ្នឹមខ្វែង** - ជាទូទៅត្រូវបានហៅថាធ្នឹមកម្រាល ជាធ្នឹមដែលភ្ជាប់គ្រោងដែស្ពា ដែលទ្រនឹងតភ្ជាប់ គ្នា។

**កម្ទេចសំណល់** - សំរាម និងវត្ថុផ្សេងទៀតដែលមិនត្រូវការ។

**ការពុកផុយ** - ការពុកផុយនៃឈើ ដែលធ្វើឲ្យវាទន់ខ្សោយ ដែលបណ្តាលមកពីភាពសើម និង ផ្សិត។

**<u>ប្លង់សេកម្រាល</u>** - ផ្នែកលើនៃរចនាសម្ព័ន្ធខាងលើនៃស្ពាន។ ប្លង់សេនេះជួយឲ្យស្ពានអាចទ្រទម្ងន់បន្ទុកដោយផ្ទាល់។ **(Fig. 1.3.3)**

**<u>ការខូចទ្រង់ទ្រាយ</u>** - ការខូចទ្រង់ទ្រាយជាអចិន្ត្រៃយ៍នៃផ្នែកនីមួយៗនៃដែកថែប អាចមានទ្រង់ ទ្រាយកោង ប៉ោង រមួល ឬរីករវែង ឬការរួមផ្សំនៃសកម្មភាពទាំងនេះ។

**ការផុយរបេះ** - ត្រូវបានកំណត់ថាជាដំណើរនៃការដាច់ពីគ្នានៃបេតុងផ្ទៃលើ ដែលត្រូវបានញែកចេញពីគ្នាយ៉ាងខ្លាំង ប៉ុន្តែមិនដាច់គ្នាទាំងស្រុងពីបេតុងខាងក្រោម ឬខាងលើទេ។

**សន្ទះ** - ធ្នឹមដែលភ្ជាប់ឃ្នាប់បេតុង និងស្ពានធ្នឹមដែក។

**ការដាច់** - គំណរលុង ឬខូចដែលអាចប៉ះពាល់ធ្ងន់ធ្ងរទៅលើកម្លាំងនៃស្ពានឈើ។

**ការធ្លាក់ខ្សោយ** - ការចុះខ្សោយនៃរូបធាតុ ឬការខូចខាតនៃបេតុងទៅជាបំណែកតូចៗ ឬភាគ ល្អិត។

**ខ្សែទឹកហូរចុះក្រោម** - ចំណុចដែលទឹកទន្លេហូរចេញពីស្ពាន។

**<u>លូ</u>** - ប្រព័ន្ធលូដែលនាំទឹកចេញ (ជាទូទៅគឺជាទឹកភ្លៀង) **(Photo 1.3.10)**

**ឃឿន** - ការលើកដីដើម្បីការពារផ្លូវថ្នល់។

**ការចាក់ដី** - ដីដែលចាក់នៅពីមុខចន្ទល់ស្ពាន។

**នឹងថ្កល់ (ថាសទ្រនាប់នឹងថ្កល់)** - មិនអាចធ្វើចលនាបាន

**ក្រចាប់តំណ** - បន្ទះឃ្នាបខាងលើ និងខាងក្រោម, ផ្នែកខាងលើ/ខាងក្រោមដែលរីកធំនៃស្ពានធ្នឹមបេតុង ឧទា. ‘AASHTO Standard I-section’ និង ‘steel I-Beam’ សម្រាប់សាងសង់ស្ពានធ្នឹមដែក។

**<u>គ្រឹះ</u>** - ផ្នែកក្រោមបំផុតនៃស្ពានដែលស្ថិតនៅក្នុងដី **(Fig. 1.3.3)**

**ការស៊ីច្រោះ** - ការខូចខាតដែលបណ្តាលមកពីការបាត់បង់ស៊ីម៉ង់ ឬភ្នាក់ងារតភ្ជាប់ ដោយសារ ការជ្រាបទឹកដែលហូរកាត់រចនាសម្ព័ន្ធ។

**<u>សំណាញ់លួស</u>** - សំណាញ់លួសដែលមានថ្ម។

**ការពាសសំណប៉ាហាំង** - ស្រទាប់ស្តើងនៃស័ង្កសីដែលពាសលើដែក ដើម្បីការពារច្រេះស៊ី។

**<u>ឃ្នាប</u>** - ធ្នឹមដែលជាទូទៅធ្វើពីដែក និងបេតុងអាម៉េ **(Fig. 1.3.2)**



**ការពាសសំណប៉ាហាំង**

**ជញ្ជាំងខណ្ឌទឹក** - ជញ្ជាំងដែលសាងសង់ឡើងដើម្បីបញ្ចៀសលំហូរទឹកទន្លេ និងការច្រាំងទន្លេ ពីសំណឹក។

**ក្បាលជញ្ជាំង** - ជញ្ជាំងនៅខាងចុងនៃលូទឹក ដើម្បីទប់ការចាក់ដីដែលនៅពីលើបំពង់លូ។

<u>**ការផ្ទុះសុល**</u> - បេតុងដែលលាយមិនបានល្អ ដែលមានប្រហោងតូចៗជាច្រើន។



ការផ្ទុះសុល

**ការប៉ះទង្គិច** - ការបុកខ្លាំង នៅពេលយានយន្តបុកបង្កាន់ដៃស្ពាន។

**ចិញ្ចើមថ្នល់** - គែមចន្លោះផ្លូវថ្នល់ និងផ្លូវដើរ។



ចិញ្ចើមថ្នល់

**ការបាក់ដី** - ការបាក់ដី និងថ្មពីលើភ្នំ។

**តំណភ្ជាប់រលុង** - តំណដែលចាប់បណ្តឹងដោយប៊ូឡុង ឬមឹន មានភាពរលុង ឬមិនបានចាប់ភ្ជាប់ ។

**ប្រព័ន្ធប្រេងរំអិល** - ប្រព័ន្ធផ្គត់ផ្គង់ប្រេង ឬខ្លាញ់រំអិលទៅលើថាសទ្រនាប់ស្ពានមេកានិច។

**ថែទាំ** - មើលថែយ៉ាងល្អ និងជួសជុលនៅពេលចាំបាច់។

**សំណង់បាយអរ** - ឥដ្ឋ ឬថ្មដែលរៀបបញ្ចូលគ្នាដោយប្រើបាយអរ។

**បេតុងឡប់ឡែ** - បេតុងដែលគ្មានបង្កប់ដែក។

**សំណើម** - មានជាតិទឹក ឬសើម។

<u>**ផ្ទុកលើសទម្ងន់**</u> - ផ្ទុកទម្ងន់ធ្ងន់ពេក។





<u>ផ្ទុកលើសទម្ងន់</u>

**ផ្ទាំង** - គ្រោង ឬបន្ទះសំប៉ែត។

**បង្កាន់ដៃស្ពាន** - ជញ្ជាំង ឬបង្កាន់ដៃតាមបណ្តោយគែមស្ពាន។

**ដែកសសៃរ** - សសៃរដែកនៅក្នុងបេតុងអាម៉េ ដើម្បីធ្វើឲ្យបេតុងរឹងមាំ។

**សសរ** - ទម្រចន្លោះចន្ទល់ស្ពាន ដែលមានលើសពីមួយចន្លោះ។ **(Fig. 1.3.2)**

**បង្គោលគ្រឹះ** - គ្រឹះវែង ស្តើងដែលបានចាក់ចូលទៅដីជ្រៅ, បង្គោលខ្វងចាក់ **(Fig. 1.3.3)**

**ជញ្ជាំងចាក់គ្រឹះ** - ជញ្ជាំងសង់ពីចំណែកសម្ភារៈវែងៗចាក់ចូលទៅក្នុងដី។

**បន្ទះ** - បន្ទះដែកសំប៉ែតរឹង

**ការប៉ាតបាយអរ** - បាយអរចន្លោះឥដ្ឋ ឬថ្មក្នុងការតម្រៀបឥដ្ឋ។

**ប្រេ៉កុងត្រាំង** - របៀបធ្វើឲ្យបេតុងរឹងមាំដោយប្រើសសៃរដែក ឬខ្សែកាបដែលបានទាញមុន។

**PTFE** - សារធាតុព័ណ៌សរអិលប្រើទៅលើថាសទ្រនាប់។

**ការលាបស្រទាប់បាយអរ** - ស្រទាប់បាយអរស្តើងប៉ាតទៅលើឥដ្ឋ ដើម្បីការពារវា។

**Reno Mattress** - សំណាញ់លួសវែង ហើយស្តើង។

**ជញ្ជាំងទប់** - ជញ្ជាំងទប់ដី

**បាតទន្លេ** - ទីបាតនៃទន្លេ

**ស្រទាប់ថ្ម** - ស្រទាប់ថ្មដែលឥតជាប់គ្នា ដើម្បីការពារច្រាំងទន្លេមិនឲ្យសឹករិចរិល។

**ច្រេះ** - អុកស៊ីតក្រហមដែលត្រូវបានបង្កើតឡើងដោយប្រតិកម្មរីដុកនៃរ៉ែដែក និងអុកស៊ីសែននៅ ពេលមានទឹក ឬសំណើមខ្យល់។

**កន្លាស់** - តង្កៀបតូចៗដែលប្រើនៅលើស្ពានដែក ដែលទប់មិនឲ្យដែកច្រនូចផ្ទាំងជ្រុះ។

**ការប្រេះបែក** - ការរបក ឬបាត់បង់ផ្នែកផ្ទៃលើនៃបេតុង ឬបាយអរ

**សំណឹក** - ការសឹករឹលនៃបាត ឬច្រាំងទន្លេ ដែលបណ្តាលមកពីការហូរទឹកទន្លេ។

**ទម្រ** - ទីកន្លែងដែលផ្នែកមួយស្ថិតនៅពីលើផ្នែកមួយទៀត។ ឧទា. ទីកន្លែងដែលថាសទ្រនាប់ ស្ថិតនៅពីលើសសរ ឬចន្ទល់។

**សេវាផ្គត់ផ្គង់** - ខ្សែកាប និងបំពង់លូដើម្បីផ្គង់ ទឹក ភ្លើងអគ្គីសនី និងទូរគមនាគមន៍ ដែលជាការ គ្រប់គ្រងរបស់ រដ្ឋាករផ្សេងទៀត។



**ការប្រេះបែក**



**សំណឹក**

**ការស្រុតចុះ** - ចលនាចុះក្រោមបន្តិចនៃរចនាសម្ព័ន្ធ។

**ជញ្ជាំងគ្រឹះបន្ទះ** - ជញ្ជាំងធ្វើពីផ្ទាំងដែក បង្គោលគ្រឹះបេតុង ឬឈើដែលខួងចូលទៅក្នុងដី ដើម្បី បង្កើតជាជញ្ជាំង។

**ភាពរួញ (នៃឈើ)** - ភាពរួញកើតឡើង នៅពេលឈើក្រៀមស្ថិតក្រោមចំណុចសរសៃឈើឆ្អែត។

**<u>កម្រាលបេតុង</u>** - ផ្ទាំងបេតុងដ៏ធំ (ឧទា. កម្រាលបេតុងស្ពាន)

**បន្ទះចន្លោះ** - បន្ទះដាក់ចន្លោះផ្នែកពីរ

**បែក** - បែកជាចម្រៀក

**កន្លែងប្រេះបែក** - កន្លែងដែលបេតុងប្រេះបែក ឧទា. ដោយសារច្រិះស៊ីដែកសរសៃក្នុងបេតុង។

**<u>ចន្លោះ</u>** - ផ្នែកនៃស្ពាន ឬចម្ងាយរវាងទម្រពីរ, ប្រវែងចន្លោះសំដៅទៅលើប្រវែងនៃស្ពាន។

**ការញែកចេញពីគ្នា** - ការញែកចេញកើតឡើងនៅពេលដែលផ្នែកខាងក្នុងស្ថិតនៅពីលើចំណុច សរសៃឆ្អែត នៅពេលស្រទាប់ខាងលើរួញ។

**គ្រឹះលាត** - គ្រឹះធំសម្រាប់សសរ ឬចន្ទល់ ដែលជាទូទៅធ្វើពីបេតុងអាម៉េ។

**<u>ចន្ទល់ជ្រែង</u>** - នៅក្នុងឃ្នាបបន្ទះដែក វាជួយទប់កុំឲ្យមានការប៉ោងផ្នែកកណ្តាល ដោយសារការ កោង ក៏ដូចជាទ្រនង់ទ្រទម្ងន់ដែលត្រូវបានផ្តល់ដោយផ្ទាល់ពីលើថាសទ្រនាប់នៅក្នុងឃ្នាបស្ពានបន្ទះដែក ដើម្បីការពារការប៉ោងនៃផ្នែកកណ្តាល ក៏ដូចជាការពារមិនការកោងនៃក្រចាប់ តំណផ្នែកខាងក្រោម។

**ការក្រាលថ្ម** - ថ្មរៀបនៅលើកំបោរស៊ីម៉ង់ ដើម្បីក្រាលពីលើជម្រាល ឬអាំងវែស័រ។

**ទ្រនង់** - ផ្នែកមួយនៃផ្នែកម្រាលដេក។

**<u>ធាតុបង្គុំរចនាសម្ព័ន្ធ</u>** - ធាតុបង្គុំទាំងអស់ដែលរួមផ្សំបង្កើតជារចនាសម្ព័ន្ធពេញលេញនៃស្ពាន។

**<u>រចនាសម្ព័ន្ធក្រោម</u>** - គ្រប់ផ្នែកខាងក្រោមស្ពានស្ពានទាំងអស់ ឬស្ថិតនៅក្រោមខ្សែរបន្ទាប់ស្នាប់ សសរវាងធ្នូ និងរួមបញ្ចូលទាំងចន្ទល់ សសរ ជញ្ជាំងក្បាលស្ពាន និងកំណោងខាងក្រោមកម្រិតខាងលើនៃទ្រនាប់ក្បាលសសរ។ **(Fig. 1.3.3)**

**<u>រចនាសម្ព័ន្ធលើ</u>** - ផ្ទៃក្រាលស្ពានទាំងមូល រួមទាំង បង្កាន់ដៃស្ពាន ដែកខ្វែង ធ្នឹម និងផ្លូវធ្វើដំណើរ **(Fig. 1.3.3)**

**ចន្លោះយោល (ឬ ចន្លោះសំយាក)** - ផ្នែកកណ្តាលនៃស្ពានខ្ពស់។

**<u>តំណឹង</u>** - ការទាញចេញពីគ្នា

**ដើមទឹក** - ទិសដៅដែលទឹកហូរមក

**<u>ការរញ្ជួយ</u>** - ចលនារញ្ជួយបន្តគ្នា ដែលបណ្តាលមកពីយានយន្តធ្ងន់ ឬរញ្ជួយដី។

**ផ្នែកភ្ជាប់** - ផ្នែកនៃឃ្នាបដែលភ្ជាប់ក្រចាប់តំណខាងក្រោម។

**រន្ធបង្ហូរទឹក** - រន្ធបង្ហូរទឹកចេញ

**ជញ្ជាំងក្បាលស្ពាន** - ជញ្ជាំងដែលស្ថិតនៅចំហៀងនៃចន្ទល់ និងផ្នែកចន្ទល់។

## < និយមន័យពាក្យបច្ចេកទេស >

**<u>តំហែទាំ</u>** - កិច្ចការវិស្វកម្មដែលធ្វើឡើងដើម្បីរក្សាដំណើរការនៃរចនាសម្ព័ន្ធស្ពាននៅកម្រិតដែល បានតម្រូវ ឬនៅកម្រិតដែលខ្ពស់ជាង ដែលកិច្ចការនេះត្រូវបានហៅជាសាមញ្ញថា "ការថែទាំ"

**ដំណើរការដែលបានតម្រូវ** - ដំណើរការដែលត្រូវបានតម្រូវសម្រាប់រចនាសម្ព័ន្ធ ដោយផ្អែកលើ គោលបំណង និងមុខងារ។

**កាលវិភាគថែទាំ** - វិធានចាំបាច់ដែលត្រូវបានជ្រើសរើសស្របតាមការវាយតម្លៃ និងការកំណត់ ដែលផ្អែកលើការត្រួតពិនិត្យ និងការថែទាំទៅលើរចនាសម្ព័ន្ធដែលចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាពនៃតម្លៃដើមនៃវដ្តជីវិត LCC (life cycle cost)។ ការថែទាំត្រូវបានកំណត់ក្នុងកាលវិភាគ ដើម្បីបញ្ចៀសការប្រមូលផ្តុំការងារក្នុងពេលណាមួយ។ (រួមបញ្ចូលទាំងតំហែទាំបង្ការ និង តំហែទាំកែតម្រូវ)

**<u>តម្លៃដើមនៃវដ្តជីវិត</u>** <u>(LCC : life cycle cost)</u> - តម្លៃដើមសរុបសម្រាប់ការងារ និងប្រតិបត្តិការថែទាំនៅពេលអនាគត។

**តំហែទាំបង្ការ** - ប្រតិបត្តិការ និងការថែទាំដែលត្រូវបានអនុវត្តក្នុងគោលបំណងបង្ការការចុះខ្សោយ ដែលធ្វើឲ្យមានការខូចខាតទៅលើដំណើរការនៃរចនាសម្ព័ន្ធ។

**តំហែទាំកែតម្រូវ** - ប្រតិបត្តិការ និងការថែទាំដែលត្រូវបានអនុវត្តស្របតាមការខូចខាតនៃដំណើរការនៃរចនាសម្ព័ន្ធ។

**រយៈពេលកំណត់ឲ្យប្រើប្រាស់** - រយៈពេលដែលបានកំណត់ឲ្យរចនាសម្ព័ន្ធប្រើប្រាស់ឡើងវិញ ដែលអាចនឹងមានការផ្លាស់ប្តូរ ដោយយោងទៅលើផែនការថែទាំដែលបានពិនិត្យឡើងវិញ។

**រយៈពេលបើកឲ្យប្រើប្រាស់** - រយៈពេលដែលរចនាសម្ព័ន្ធ ឬធាតុបង្គុំដែលអាចដំណើរការពេញលេញ។ រយៈពេលនេះត្រូវបានកំណត់ក្នុងអំឡុងពេលសាងសង់។

**រយៈពេលកំណត់ឲ្យប្រើប្រាស់ដែលនៅសល់** - រយៈពេលចាប់ពីការត្រួតពិនិត្យ ឬការសិក្សា រហូតដល់បញ្ចប់រយៈពេលកំណត់ឲ្យប្រើប្រាស់។

**រយៈពេលបើកឲ្យប្រើប្រាស់ដែលនៅសល់** - រយៈពេលចាប់ពីការត្រួតពិនិត្យ ឬការសិក្សា រហូតដល់បញ្ចប់រយៈពេលបើកឲ្យប្រើប្រាស់។

**មុខងារនៃរចនាសម្ព័ន្ធ (ធាតុបង្គុំ)** - មុខងារដែលរចនាសម្ព័ន្ធ (ធាតុបង្គុំ) អនុវត្តស្របតាមគោល បំណង ឬតម្រូវការ។

**ដំណើរការនៃរចនាសម្ព័ន្ធ (ធាតុបង្គុំ)** - ដំណើរការនៃរចនាសម្ព័ន្ធ (ធាតុបង្គុំ) ស្របតាមគោល បំណង ឬតម្រូវការ។

**ភាពធន់** - ភាពធន់នៃរចនាសម្ព័ន្ធទៅនឹងការខូចខាតក្នុងពេលខាងមុខ ដែលបណ្តាលមកពីការ ធ្លាក់ចុះនៃសម្ភារៈនៃរចនាសម្ព័ន្ធក្រោមលក្ខខណ្ឌធម្មតា។

**សុវត្ថិភាព** - ដំណើរការរចនាសម្ព័ន្ធដែលការពារជីវិតមនុស្ស និងទ្រព្យសម្បត្តិរបស់អ្នកប្រើប្រាស់ និងភាគីទីបីពីការខូចខាត។

**ភាពដែលអាចប្រើប្រាស់បាន** - ដំណើរការនៃរចនាសម្ព័ន្ធដែលជួយឲ្យអ្នកប្រើប្រាស់បញ្ហារចនា សម្ព័ន្ធដោយសេរី ឬដែលការពារផលប៉ះពាល់អវិជ្ជមានទៅកាន់បរិដ្ឋានជុំវិញ និងដំណើរការ សម្រាប់គោលបំណងថែទាំឲ្យបានត្រឹមត្រូវដល់មុខងារផ្សេងទៀត ដែលតម្រូវចាំបាច់សម្រាប់ រចនាសម្ព័ន្ធ។

**ផលប៉ះពាល់លើភាគីទីបី** - កម្រិតនៃផលប៉ះពាល់ទៅលើទ្រព្យសម្បត្តិ ឬរបួសស្នាមរបស់បុគ្គល ម្នាក់ ដែលបណ្តាលមកពីបំណែកបេតុងជាច់ពីរចនាសម្ព័ន្ធដែលធ្លាក់លើ។

**<u>ការត្រួតពិនិត្យ</u>** - ពាក្យរួមសម្រាប់ការពិនិត្យវិភាគ ដើម្បីស្វែងរកមើលភាពមិនប្រក្រតីនៅលើ រចនាសម្ព័ន្ធ ឬធាតុបង្គុំ។

**<u>ការតាមដាន</u>** - ដើម្បីសង្កេតអំពីលក្ខខណ្ឌនៃរចនាសម្ព័ន្ធ និងធាតុបង្គុំតាមរយៈអង្គញាណ (sensor) ដែលបានតម្លើងនៅលើរចនាសម្ព័ន្ធ និងធាតុបង្គុំ។

**<u>ការជួសជុល</u>** - វិធាននានាដែលត្រូវបានធ្វើឡើងដើម្បីដកចេញនូវការប៉ះទង្គិចទៅលើភាគីទីបី ឬ ស្តារ/លើកកម្ពស់សម្រស់នៃរចនាសម្ព័ន្ធ ឬលើកកម្ពស់ភាពធន់។ វិធានទាំងនេះរួមមាន វិធាន ដើម្បីស្តារសុវត្ថិភាព ឬភាពអាចប្រើប្រាស់បាន (ដំណើរការមេកានិច) ទៅដល់កម្រិតមួយដែលរចនាសម្ព័ន្ធមាន នៅពេលទើបតែសាងសង់រួច។

**<u>ការពង្រឹង</u>** - វិធានក្នុងការស្តារសុវត្ថិភាព ឬភាពអាចប្រើប្រាស់បាន (ដំណើរការមេកានិច) ឲ្យ ដល់កម្រិតមួយខ្ពស់ជាងនៅពេលសាងសង់ដំបូង។

**<u>ភាពខ្វះចន្លោះ</u>** - ពាក្យរួមមួយសម្រាប់កំហុសបឋម ការខូច និងការធ្លាក់ខ្សោយ។

**កំហុសបឋម** - ស្នាមប្រេះ ប្រហោងខ្វត និងការប៉ះប៉ូវបេតុង ដែលកើតឡើងនៅពេលសាងសង់

**<u>ការខូចខាត</u>** - ការខូចខាតដែលកើតឡើងក្នុងរយៈពេលខ្លី ដោយសាររញ្ជួយដី ឬការប៉ះទង្គិច ហើយមិនបន្តខូចខាតទៅមុនទៀត នៅពេលពេលវេលាកន្លងទៅមុខ។

**<u>ការចុះខ្សោយ</u>** - ការចុះខ្សោយនៅពេលពេលវេលាចេះតែធ្វើដំណើរទៅមុខ។

**ភាពរឹងមាំ** - កម្រិតនៃដំណើរការបច្ចុប្បន្នធៀបនឹងដំណើរការដែលត្រូវការចាំបាច់ សម្រាប់រចនា សម្ព័ន្ធ។

# ជំពូកទី 2 ការរៀបចំសម្រាប់តំហែទាំស្ពាន

## 2.1 គម្រោងសង្ខេប

ដូចបានរៀបរាប់ក្នុងជំពូក 1 អញ្ចឹង វាគឺជាការសំខាន់ដែលត្រូវធ្វើការថៃទាំរចនាសម្ព័ន្ធស្ពានជាប្រចាំ ដើម្បីឲ្យមាននិរន្តភាព ហើយវាជាការចាំបាច់ដែលយើងត្រូវបង្កើតវដ្តគ្រប់គ្រងមួយជាមូលដ្ឋាន និងអាចធ្វើបាន ដូចមានបង្ហាញក្នុង **Fig. 2.1.1**




**Fig. 2.1.1 វដ្តនៃការថៃទាំស្ពានជាប្រចាំ**

ដើម្បីអនុវត្តវដ្តនៃការថៃទាំស្ពានជាប្រចាំក្នុងលក្ខណៈមួយដែលមាននិរន្តភាព វាជាការសំខាន់ ដែលយើងត្រូវកំណត់ទុកជាមុនអំពីអង្គភាពដែលមានទំនួលខុសត្រូវ នៅក្នុងនាយកដ្ឋានដែលពាក់ព័ន្ធសម្រាប់ផ្នែកនីមួយៗនៃវដ្តថៃទាំ។ បន្ថែមពីលើនេះទៀត ទំហំនៃទំនួលខុសត្រូវ និង កាលវិភាគថៃទាំប្រចាំឆ្នាំគួរតែមានចែងនៅក្នុងឯកសារជាផ្លូវការមួយ ដែលមានប្រយោជន៍ក្នុងការផ្សព្វផ្សាយចំណេះដឹងក្នុងចំណោមអង្គភាពដែលទទួលខុសត្រូវ។

ជំពូកបន្តបន្ទាប់ចែងអំពីផ្នែកនៃការត្រួតពិនិត្យដែលជាផ្នែកស្នូលមួយនៃការថៃទាំស្ពាន និងបញ្ជាក់ប្រាប់អំពីអង្គភាពដែលទទួលខុសត្រូវ លើកិច្ចការត្រួតពិនិត្យនីមួយៗ និងនីតិវិធីបទដ្ឋាន។

គួរកត់សម្គាល់ថា អង្គភាពនីមួយៗមិនឯករាជ្យពីអង្គភាពដទៃទេ ហើយការសហការរួមគ្នាគឺជាគន្លឹះដើម្បីទទួលបានលំហូរនៃវដ្តត្រួតពិនិត្យដែលរលូន។ អង្គភាពនីមួយៗគួរតែឆ្លើយតបឲ្យ បានត្រឹមត្រូវ និងស្មោះពីចិត្ត ចំពោះសំណើរពីអង្គភាពពាក់ព័ន្ធ។ សំណើរនេះគួរតែបង្ហាញដោយមានកាលវេលាកំណត់ និងមានភាពច្បាស់លាស់តាមតែអាចធ្វើទៅបាន។

បន្ថែមពីលើនេះទៀត ដើម្បីផ្លាស់ប្តូរព័ត៌មាន បញ្ហាពិបាក និងវិធានការដែលចាំបាច់ត្រូវធ្វើក្នុង ចំណោមអង្គភាពពាក់ព័ន្ធ យើងមានការណែនាំខ្ពស់ចំពោះការរៀបចំការប្រជុំរួមគ្នាជាប្រចាំ។ ព័ត៌មានអំពីបច្ចេកវិទ្យាត្រូវតែពិនិត្យត្រូវបានផ្សព្វផ្សាយ មានការផ្តល់ព័ត៌មានអំពីការខូចខាត និងមានការរៀបផែនការទៅលើប្រភេទចាំបាច់ដែលត្រូវជួសជុល។

តារាងនៃការរៀបចំនៃនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងនាយកដ្ឋានសាធារណការ និងដឹកជញ្ជូន ត្រូវបានបង្ហាញក្នុងរូបភាព **Fig. 2.1.2** និងរូបភាព **Fig. 2.1.2** ។




**Fig. 2.1.2 អង្គការលេខនៃនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់**




**Fig. 2.1.3 អង្គការលេខនៃនាយកដ្ឋានសាធារណការ និងដឹកជញ្ជូនក្នុងខេត្តកណ្តាល**

## 2.2 កាលវិភាគ

ផែនការសកម្មភាពប្រចាំឆ្នាំសម្រាប់ការត្រួតពិនិត្យត្រូវបានបង្ហាញក្នុងរូបភាព **Fig. 2.2.1** វាគឺជាការល្អដែលយើងត្រូវបំពេញសកម្មភាពនីមួយៗ ដោយឆ្លុះបញ្ចាំងទៅលើកាលវិភាគនេះ។




**Fig. 2.2.1 កាលវិភាគចាត់ចែងថវិកាដើម្បីធ្វើការត្រួតពិនិត្យ និងថែទាំ**

MPWT: ក្រសួងសាធារណការ និងដឹកជញ្ជូន

DPWT: នាយកដ្ឋានសាធារណការ និងដឹកជញ្ជូន

MEF: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## 2.3 ផែនសមត្ថកិច្ច

### 2.3.1 ការត្រួតពិនិត្យស្ពាន

នៅពេលធ្វើការត្រួតពិនិត្យស្ពាន ទំនួលខុសត្រូវខាងក្រោមក្នុងការត្រួតពិនិត្យស្ពានមានភាពចាំ បាច់ ដែលត្រូវចាត់តាំងដល់អង្គភាពជាក់លាក់ណាមួយ។

**(a) ផែនការអនុវត្តប្រចាំឆ្នាំ**

**(b) ការប៉ាន់ស្មានថ្លៃចំណាយ**

**(c) ការគ្រប់គ្រងថវិកា**

**(d) ការអនុវត្តន៍**

**(e) ទីប្រឹក្សាបច្ចេកទេស**

#### (a) ផែនការអនុវត្តប្រចាំឆ្នាំ

ផែនការអនុវត្តប្រចាំឆ្នាំរួមបញ្ចូល "ទីតាំងត្រួតពិនិត្យស្ពាន ទំហំ វិធីសាស្ត្រ និងកាលវិភាគ" និង រួមទាំងថវិកាប៉ាន់ស្មានសម្រាប់ការត្រួតពិនិត្យ ដែលត្រូវបានរៀបចំនៅក្នុងផ្នែក (b)។ ផែនការនេះត្រូវបានប្រើដើម្បីស្នើសុំថវិកា និងសម្រាប់ធ្វើការចរចាជាមួយក្រសួងសេដ្ឋកិច្ច និងហរិញ្ញ វត្ថុ។ ផែនការនេះត្រូវពិចារណាអំពីលក្ខខណ្ឌមាត្រសាស្ត្រ ដូចជា ព្យុះ និងទឹកជំនន់ និងត្រូវត្រៀមអនុវត្តឲ្យមានប្រសិទ្ធផល។

អង្គភាពទទួលខុសត្រូវ និងដំណើរការរៀបចំមានដូចខាងក្រោម៖

1) ផែនការអនុវត្តប្រចាំឆ្នាំត្រូវបានរៀបចំដោយ**ការិយាល័យសាធារណការនីមួយៗ នៃនាយក ដ្ឋានសាធារណៈ និងដឹកជញ្ជូន** ដោយពិនិត្យមើលឯកសារយោងស្តីពីការត្រួតពិនិត្យ និង កំណត់ត្រាត្រួតពិនិត្យពីមុន។ ផែនការនេះត្រូវបញ្ជូនទៅ**ការិយាល័យបញ្ជីសារពើភ័ណ្ឌផ្លូវថ្នល់ និងតំហែទាំជាប្រចាំនៃនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ នៃក្រសួងសាធារណៈការ និងដឹកជញ្ជូន**។
2) ដើម្បីប្រមូលព័ត៌មានចាំបាច់ សម្រាប់ធ្វើការចរចាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **ការិយាល័យបញ្ជីសារពើភ័ណ្ឌផ្លូវថ្នល់ និងតំហែទាំជាប្រចាំ**សួរសំណួរ និងទទួលចម្លើយពី **ការិយាល័យសាធារណៈការ**នីមួយៗ អំពីព័ត៌មានទាំងនោះ ប្រសិនបើមាន។
3) **ការិយាល័យបញ្ជីសារពើភ័ណ្ឌផ្លូវថ្នល់ និងតំហែទាំជាប្រចាំ**សង្ខេបទៅលើព័ត៌មានដែលប្រមូលបាន និងកែសម្រួលវា ដើម្បីធ្វើជាផែនការ។

ការកំណត់ពេលវេលាត្រួសៗអំពីសកម្មភាពដែលបានរៀបរាប់ខាងលើ ត្រូវបានបង្ហាញនៅក្នុង **Fig. 2.2.1**។ កាលបរិច្ឆេទកំណត់ជាក់លាក់នៃការបញ្ជូនឯកសារត្រូវផ្តល់ព័ត៌មានដោយ**ការិយាល័យបញ្ជីសារពើភ័ណ្ឌផ្លូវថ្នល់ និងតំហែទាំជាប្រចាំ** ជារៀងរាល់ឆ្នាំ។

**Table 2.3.1 អង្គភាពទទួលខុសត្រូវលើផែនការអនុវត្តប្រចាំឆ្នាំ**

| មាតិកា | អង្គភាពទទួលខុសត្រូវ | ផ្នែកពាក់ព័ន្ធ |
|---|---|---|
| 1) ដើម្បីរៀបចំផែនការអនុវត្តប្រចាំឆ្នាំ | ការិយាល័យសាធារណការ, នាយកដ្ឋានសាធារណការ និង ដឹកជញ្ជូន | ការិយាល័យបញ្ជីសារពើភ័ណ្ឌផ្លូវថ្នល់ និងតំហែទាំជាប្រចាំនៃនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ |
| 2) ដើម្បីសួរសំណួរ និងទទួលចម្លើយអំពីផែនការ | ការិយាល័យបញ្ជីសារពើភ័ណ្ឌផ្លូវថ្នល់ និងតំហែទាំជាប្រចាំនៃនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ | ការិយាល័យសាធារណការ, នាយកដ្ឋានសាធារណការ និងដឹកជញ្ជូន |
| 3) ដើម្បីប្រមូលព័ត៌មាន និងកែសម្រួល | ការិយាល័យបញ្ជីសារពើភ័ណ្ឌផ្លូវថ្នល់ និងតំហែទាំជាប្រចាំនៃនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ | ការិយាល័យសាធារណការ, នាយកដ្ឋានសាធារណការ និងដឹកជញ្ជូន |




**Fig. 2.3.1 រូបភាពនៃផែនការអនុវត្តប្រចាំឆ្នាំ**

## (b) ការប៉ាន់ស្មានថ្លៃចំណាយ

ថ្លៃចំណាយដែលត្រូវបានប៉ាន់ស្មានត្រឹមត្រូវ គឺជាឯកសារយោងគន្លឹះសម្រាប់ការចរចាជាមួយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អង្គភាពទទួលខុសត្រូវ និងដំណើរការរៀបចំមានដូចខាងក្រោម៖

1) ថ្លៃចំណាយត្រូវធ្វើការប៉ាន់ស្មានដោយ**ការិយាល័យគណនេយ្យផែនការនៃនាយកដ្ឋានសាធារណការ និងដឹកជញ្ជូន** ផ្អែកលើផែនការអនុវត្តប្រចាំឆ្នាំ។ ថ្លៃចំណាយប៉ាន់ស្មានត្រូវ បញ្ជូនទៅ**ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុនៃនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់**។

2) **<u>ការិយាល័យសំភារៈផ្លូវ និងវដ្តនៃការជួសជុល</u>** សួរសំណួរ និងទទួលចម្លើយពី**ការិយាល័យគណនេយ្យផែនការ**នីមួយៗ ទៅលើកិច្ចការដែលទាក់ទងនឹងថ្លៃចំណាយ ប្រសិនបើមាន។

3) **<u>ការិយាល័យសំភារៈផ្លូវ និងវដ្តនៃការជួសជុល</u>** សង្ខេប និងកែសម្រួលប័ណ្ណឯកសារបរិមាណ។

ការកំណត់ពេលវេលាត្រួសៗអំពីសកម្មភាពដែលបានរៀបរាប់ខាងលើ ត្រូវបានបង្ហាញនៅក្នុង **Fig. 2.2.1**។ កាលបរិច្ឆេទកំណត់ជាក់លាក់នៃការបញ្ជូនឯកសារត្រូវផ្តល់ព័ត៌មានដោយ**<u>ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ</u>** ជារៀងរាល់ឆ្នាំ។

**Table 2.3.2 អង្គភាពទទួលខុសត្រូវលើការប៉ាន់ស្មានថ្លៃចំណាយ**

| មាតិកា | អង្គភាពទទួលខុសត្រូវ | ផ្នែកពាក់ព័ន្ធ |
|---|---|---|
| 1) ដើម្បីប៉ាន់ស្មានថ្លៃចំណាយ | ការិយាល័យគណនេយ្យផែនការនៃនាយកដ្ឋានសាធារណការ និងដឹកជញ្ជូន | ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុនៃនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ |
| 2) ដើម្បីសួរសំណួរ និងទទួលចម្លើយអំពីការប៉ាន់ស្មានថ្លៃចំណាយ | ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុនៃនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ | ការិយាល័យគណនេយ្យផែនការនៃនាយកដ្ឋានសាធារណការ និងដឹកជញ្ជូន |
| 3) ដើម្បីសង្ខេប និងកែសម្រួលការប៉ាន់ស្មាន | ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុនៃនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ | ការិយាល័យគណនេយ្យផែនការនៃនាយកដ្ឋានសាធារណការ និងដឹកជញ្ជូន |




**Fig. 2.3.2 រូបភាពនៃការប៉ាន់ស្មានថ្លៃចំណាយ**

### (c) ការគ្រប់គ្រងថវិកា

ការគ្រប់គ្រងឲ្យបានត្រឹមត្រូវទៅលើថវិកាដែលបានទទួល សម្រាប់ធ្វើការត្រួតពិនិត្យផ្លូវថ្នល់ជួយការពារមិនឲ្យខ្វះខាតលើការចំណាយសម្រាប់ការត្រួតពិនិត្យ និងប្រតិកម្មអវិជ្ជមានដែល កើតឡើងពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលអាចនឹងបង្កបញ្ហាសម្រាប់សំណើរថវិកានៅពេលក្រោយ។ ហេតុដូច្នេះហើយ គួរតែមានការត្រួតពិនិត្យជាប្រចាំ និងការបញ្ជាក់លើការ អនុវត្តថវិកា ប្រសិនបើមានការចំណាយទៅលើគោលបំណងមិនពាក់ព័ន្ធ ឬមានការប្រើប្រាស់ ថវិកាខុស។ អង្គភាពទទួលខុសត្រូវ និងដំណើរការរៀបចំមានដូចខាងក្រោមៈ

1) **<u>ការិយាល័យបញ្ជីសារពើភ័ណ្ឌផ្លូវថ្នល់ និងតំហែទាំជាប្រចាំនៃនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់</u>**មានទំនួលខុសត្រូវក្នុងការចាត់ចែងថវិកាជាតិទាំងមូល ហើយ**<u>ការិយាល័យគណនេយ្យផែនការនីមួយៗនៃនាយកដ្ឋានសាធារណការ និងដឹកជញ្ជូន</u>**ចាត់ចែងថវិកានៃ ដែនសមត្ថកិច្ចដែលទទួលខុសត្រូវ។
2) នៅត្រឹមចុងខែកញ្ញា **<u>ការិយាល័យបញ្ជីសារពើភ័ណ្ឌផ្លូវថ្នល់ និងតំហែទាំជាប្រចាំ</u>**ត្រួតពិនិត្យ និងបញ្ជាក់អំពីតុល្យភាពរវាងថវិកា និងការចំណាយជាក់ស្តែងក្នុង**<u>ការិយាល័យគណនេយ្យផែនការ</u>**នីមួយៗ។ ប្រសិនបើរកឃើញនូវការខ្វះខាតណាមួយ **<u>ការិយាល័យបញ្ជីសារពើភ័ណ្ឌផ្លូវថ្នល់ និងតំហែទាំជាប្រចាំ</u>**ត្រូវធ្វើការបែងចែកថវិកាសាជាថ្មី។

**Table 2.3.3 អង្គភាពទទួលខុសត្រូវចាត់ចែងថវិកា**

| មាតិកា | អង្គភាពទទួលខុសត្រូវ | ផ្នែកពាក់ព័ន្ធ |
|---|---|---|
| 1) ការចាត់ចែងថវិកាជាតិទាំងមូល | ការិយាល័យបញ្ជីសារពើភ័ណ្ឌផ្លូវថ្នល់និងតំហែទាំជាប្រចាំនៃនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ | ការិយាល័យគណនេយ្យផែនការនៃនាយកដ្ឋានសាធារណការ និងដឹកជញ្ជូន |
| 2) ត្រួតពិនិត្យ និងបញ្ជាក់អំពីតុល្យភាពរវាងថវិកា និងការចំណាយជាក់ស្តែង | ការិយាល័យបញ្ជីសារពើភ័ណ្ឌផ្លូវថ្នល់ និងតំហែទាំជាប្រចាំនៃនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ | ការិយាល័យគណនេយ្យផែនការនៃនាយកដ្ឋានសាធារណការ និងដឹកជញ្ជូន |




**Fig. 2.3.3 រូបភាពនៃការចាត់ចែងថវិកា**

## (d) ការអនុវត្ត

វិធីសាស្រ្តនៃការត្រួតពិនិត្យត្រូវបានបង្ហាញក្នុង "ជំពូក ៣៖ តម្រូវការទូទៅក្នុងការត្រួតពិនិត្យ ស្ពាន"។ អង្គភាពទទួលខុសត្រូវ និងដំណើរការរៀបចំមានដូចខាងក្រោម៖

1) ការត្រួតពិនិត្យស្ពានត្រូវបានធ្វើឡើងដោយអ្នកត្រួតពិនិត្យដែលបានចាត់តាំង ដែលមកពី **<u>អង្គភាពផ្លូវថ្នល់ និងស្ពាននៃនាយកដ្ឋានសាធារណការ និងដឹកជញ្ជូន</u>** ទោះបីជាមានការខូច ខាត ឬគ្មានក៏ដោយ **<u>អ្នកត្រួតពិនិត្យ</u>**ត្រូវចុះលទ្ធផលនៃការត្រួតពិនិត្យនៅក្នុងប្រព័ន្ធទិន្នន័យ ត្រួតពិនិត្យស្ពាន។
2) សម្រាប់ការចាត់ចែងថវិកាត្រួតពិនិត្យ **<u>អង្គភាពផ្លូវថ្នល់ និងស្ពាន</u>**នីមួយៗត្រូវតែរាយការណ៍ អំពីថ្លៃចំណាយត្រួតពិនិត្យជាក់ស្តែង ទៅកាន់**<u>ការិយាល័យគណនេយ្យផែនការនៃនាយក ដ្ឋានសាធារណការ និងដឹកជញ្ជូន</u>** ក្នុងរយៈពេលមួយសប្តាហ៍បន្ទាប់ពីការចំណាយរួច។
3) ប្រសិនបើមានការសន្មត់ថាមានការចំណាយលើសពីថវិកា **<u>អង្គភាពផ្លូវថ្នល់ និងស្ពាន</u>**ត្រូវតែ រាយការណ៍ទៅ **<u>ការិយាល័យគណនេយ្យផែនការ</u>**ជាមុន។

Table 2.3.4 អង្គភាពទទួលខុសត្រូវលើការអនុវត្ត

| មាតិកា | អង្គភាពទទួលខុសត្រូវ | ផ្នែកពាក់ព័ន្ធ |
|---|---|---|
| 1) ធ្វើការត្រួតពិនិត្យស្ពាន | អង្គភាពផ្លូវថ្នល់ និងស្ពាននៃនាយកដ្ឋានសាធារណការ និងដឹកជញ្ជូន | — |
| 2) រាយការណ៍អំពីថ្លៃចំណាយលើការត្រួត ពិនិត្យជាក់ស្តែង | អង្គភាពផ្លូវថ្នល់ និងស្ពាននៃនាយកដ្ឋានសាធារណការ និងដឹកជញ្ជូន | ការិយាល័យគណនេយ្យផែនការនៃនាយកដ្ឋានសាធារណការ និងដឹកជញ្ជូន |
| 3) រាយការណ៍អំពីថ្លៃចំណាយលើការត្រួត ពិនិត្យ (ក្នុងករណីមានការចំណាយលើស) | អង្គភាពផ្លូវថ្នល់ និងស្ពាននៃនាយកដ្ឋានសាធារណការ និងដឹកជញ្ជូន | ការិយាល័យគណនេយ្យផែនការនៃនាយកដ្ឋានសាធារណការ និងដឹកជញ្ជូន |




Fig. 2.3.4 រូបភាពនៃការអនុវត្ត

### (e) ទីប្រឹក្សាបច្ចេកទេស

នៅពេលសម្ភារៈរចនាសម្ព័ន្ធថ្មីត្រូវបានបន្ថែមទៅលើស្ពានណាមួយ ហើយអ្នកត្រួតពិនិត្យត្រូវការការណែនាំខ្លះទៅលើវិធីសាស្រ្តនៃការត្រួតពិនិត្យ ពួកគេអាចទាក់ទងជាមួយនាយកដ្ឋានដែលបានចាត់តាំង ដើម្បីទទួលជំនួយផ្នែកបច្ចេកទេស។ អង្គភាពទទួលខុសត្រូវ និងដំណើរ ការនៃការរៀបចំមានដូចតទៅ៖

1) **ការិយាល័យផែនការ និងបច្ចេកទេសផ្លូវថ្នល់ និងស្ពាននៃនាយកដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់** និង**ការិយាល័យ ការិយាល័យបញ្ជីសារពើភ័ណ្ឌផ្លូវថ្នល់ និងតំហែទាំជាប្រចាំនៃនាយកដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់** គឺជាអ្នកទទួល

ខុសត្រូវសម្រាប់ការផ្តល់ប្រឹក្សាផ្នែក បច្ចេកទេស។

2) **ការិយាល័យផែនការ និងបច្ចេកទេស** និង**ការិយាល័យការិយាល័យបញ្ជីសារពើភ័ណ្ឌផ្លូវថ្នល់ និងតំហែទាំជាប្រចាំ** ត្រូវតែកត់ត្រាព័ត៌មាននៃការប្រឹក្សាសម្រាប់ទុកជាឯកសារយោងនៅពេលអនាគតសម្រាប់ករណីដែលស្រដៀងគ្នា និងទុកជាព័ត៌មានបឋម ដើម្បីធ្វើកែសម្រួលសៀវភៅណែនាំអំពីការថែទាំស្ពាន។

**Table 2.3.5 អង្គភាពទទួលខុសត្រូវផ្នែកផ្តល់ប្រឹក្សាបច្ចេកទេស**

| មាតិកា | អង្គភាពទទួលខុសត្រូវ | ផ្នែកពាក់ព័ន្ធ |
|---|---|---|
| 1) ក្រុមប្រឹក្សាបច្ចេកទេស | ការិយាល័យផែនការ និងបច្ចេកទេសសម្រាប់ផ្លូវថ្នល់ និងស្ពាននៃនាយកដ្ឋានហេដ្ឋារចនា សម្ព័ន្ធផ្លូវថ្នល់ និងការិយាល័យ បញ្ជីសារពើភ័ណ្ឌផ្លូវថ្នល់ និងតំហែទាំជាប្រចាំនៃនាយកដ្ឋានហេដ្ឋារចនា សម្ព័ន្ធផ្លូវថ្នល់ | នាយកដ្ឋានសាធារណការ និងដឹកជញ្ជូន, ក្រសួងសាធារណការ និងដឹកជញ្ជូន |
| 2) ដើម្បីកត់ត្រាព័ត៌មានអំពីការប្រឹក្សា | ការិយាល័យផែនការ និងបច្ចេកទេសសម្រាប់ផ្លូវថ្នល់ និងស្ពាននៃនាយកដ្ឋានហេដ្ឋារចនា សម្ព័ន្ធផ្លូវថ្នល់ និងការិយាល័យ បញ្ជីសារពើភ័ណ្ឌផ្លូវថ្នល់ និងតំហែទាំជាប្រចាំនៃនាយកដ្ឋានហេដ្ឋារចនា សម្ព័ន្ធផ្លូវថ្នល់ | នាយកដ្ឋានសាធារណការ និងដឹកជញ្ជូន, ក្រសួងសាធារណការ និងដឹកជញ្ជូន |

## 2.3.2 ការកត់ត្រាអំពីការត្រួតពិនិត្យស្ពាន

លទ្ធផលកត់ត្រាអំពីការត្រួតពិនិត្យស្ពានគឺជាប្រភពព័ត៌មានដ៏សំខាន់ ក្នុងការថែរក្សាស្ពានឲ្យ មានសុខភាពល្អ ជាមួយនឹងសកម្មភាពថែទាំស្ពានដែលមានស្ថិរភាព ដូចជា ការវិភាគអំពីការ ខូចខាត ការរៀបផែនការជួសជុល និងការរៀបចំថវិកា។ លទ្ធផលដែលត្រូវបានបញ្ចូលក្នុង ប្រព័ន្ធទិន្នន័យអំពីការត្រួតពិនិត្យស្ពាន់ មិនមែនគ្រាន់តែរួម បញ្ចូលកម្រិតនៃការខូចខាតប៉ុណ្ណោះ ទេ ប៉ុន្តែស្ថានភាពដែលគ្មានការខូចខាតផងដែរ ព្រោះទិន្នន័យនៃស្ថានភាព បច្ចុប្បន្ន ទោះបីគ្មាន ការខូចខាតក៏ដោយ គឺជាព័ត៌មានចាំបាច់ដើម្បីធ្វើការប៉ាន់ស្មានត្រួសៗអំពីរយៈពេលដែល កើត ឡើង នៅពេលរកឃើញអំពីការខូចខាត។ នៅពេលធ្វើការត្រួតពិនិត្យស្ពាន ទំនួលខុសត្រូវនៃការត្រួតពិនិត្យ ស្ពានខាងក្រោម មានភាពចាំបាច់ក្នុងចាត់តាំងដល់អង្គភាពជាក់លាក់ណាមួយ។

**(a) ការបញ្ចូលទិន្នន័យអំពីលទ្ធផលនៃការត្រួតពិនិត្យ**

**(b) ការបញ្ជាក់អំពីការបញ្ចូលទិន្នន័យ**

**(c) ការគ្រប់គ្រងមូលដ្ឋានទិន្នន័យ**

**(a) ការបញ្ចូលទិន្នន័យអំពីលទ្ធផលនៃការត្រួតពិនិត្យ**

**(a) ការបញ្ចូលទិន្នន័យអំពីលទ្ធផលនៃការត្រួតពិនិត្យ**

1) អ្នកត្រួតពិនិត្យក្នុង**<u>អង្គភាពផ្លូវថ្នល់ និងស្ពាននីមួយៗនៃនាយកដ្ឋានសាធារណការ និងដឹក ជញ្ជូន</u>** ត្រូវទទួលខុសត្រូវក្នុងការបញ្ចូលទិន្នន័យលទ្ធផលនៃការត្រួតពិនិត្យ ទៅក្នុងប្រព័ន្ធ មូលដ្ឋានទិន្នន័យត្រួតពិនិត្យស្ពាន។ វាជាការល្អក្នុងការបញ្ចូលទិន្នន័យនៅត្រង់កន្លែងតែម្តង បន្ទាប់ពីការត្រួតពិនិត្យរួច លើកលែងតែស្ថានភាពទីតាំងមិនអនុញ្ញាត។

**Table 2.3.6 អង្គភាពទទួលខុសត្រូវក្នុងការបញ្ចូលទិន្នន័យ**

| មាតិកា | អង្គភាពទទួលខុសត្រូវ | ផ្នែកពាក់ព័ន្ធ |
|---|---|---|
| 1) បញ្ចូលទិន្នន័យលទ្ធផលត្រួតពិនិត្យទៅក្នុងប្រព័ន្ធមូលដ្ឋានទិន្នន័យត្រួតពិនិត្យស្ពាន | អ្នកត្រួតពិនិត្យ (អង្គភាពផ្លូវថ្នល់ និងស្ពាននៃនាយកដ្ឋានសាធារណការ និងដឹក ជញ្ជូន) | — |

### (b) ការបញ្ជាក់អំពីការបញ្ចូលទិន្នន័យ

ការបញ្ជាក់ត្រូវបានធ្វើឡើងដើម្បីឲ្យប្រាកដថា ថវិកាដែលបានទទួលត្រូវបានអនុវត្តត្រឹមត្រូវ ដោយគ្មានលម្អៀងទៅលើកិច្ចការដែលមិនសមរម្យណាមួយ។ ដំណើរការនេះពិតជាមានប្រយោជន៍ ដើម្បីទទួលបានទំនាក់ទំនងដែលមានទំនុកចិត្តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ដើម្បីធ្វើការសម្របសម្រួលការចរចាអំពីថវិកានៅពេលអនាគត។ អង្គភាពទទួលខុសត្រូវ និង ដំណើរការរៀបចំមានដូចខាងក្រោមៈ

1) <u>**ប្រធានក្រុមត្រួតពិនិត្យ**</u>មានទំនួលខុសត្រូវក្នុងការបញ្ជាក់អំពីការបញ្ចូលទិន្នន័យ។ ការត្រួត ពិនិត្យកម្រិតមធ្យមដើម្បីរកមើលតុល្យភាពរវាងកាលវិភាគដំបូងក្នុងផែនការអនុវត្តការត្រួត ពិនិត្យ និងការរីកចម្រើនជាក់ស្តែងត្រូវធ្វើឡើងក្នុងខែធ្នូ។

**Table 2.3.7 អង្គភាពទទួលខុសត្រូវលើការបញ្ជាក់**

| មាតិកា | អង្គភាពទទួលខុសត្រូវ | ផ្នែកពាក់ព័ន្ធ |
|---|---|---|
| 1) ការបញ្ជាក់លើកការបញ្ចូលទិន្នន័យ | ប្រធានក្រុមត្រួតពិនិត្យ | អ្នកត្រួតពិនិត្យ |

### (c) ការគ្រប់គ្រងមូលដ្ឋានទិន្នន័យ

ម៉ាស៊ីនបម្រើមូលដ្ឋានទិន្នន័យនៃប្រព័ន្ធមូលដ្ឋានទិន្នន័យត្រួតពិនិត្យស្ពាន ត្រូវស្ថិតនៅក្នុងប្រព័ន្ធទិន្នន័យនៃនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់។ អង្គភាពទទួលខុសត្រូវ និងដំណើរការនៃការរៀបចំមានដូចខាងក្រោមៈ

1) <u>**ការិយាល័យគ្រប់គ្រងទិន្នន័យ ឧបករណ៍ និងសម្ភារៈនៃនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់**</u>មានទំនួលខុសត្រូវក្នុងការគ្រប់គ្រងម៉ាស៊ីនបម្រើមូលដ្ឋានទិន្នន័យ។ ម៉ាស៊ីនបម្រើត្រូវតែ មានរក្សាឲ្យសកម្មជាប់ជានិច្ច ដើម្បីឲ្យគ្រប់គ្នាអាចចូលទៅក្នុងប្រព័ន្ធ ដើម្បីបញ្ចូលទិន្នន័យ និងយោងឯកសារគ្រប់ពេលវេលា។

**Table 2.3.8 អង្គភាពទទួលខុសត្រូវលើការគ្រប់គ្រងមូលដ្ឋានទិន្នន័យ**

| មាតិកា | អង្គភាពទទួលខុសត្រូវ | ផ្នែកពាក់ព័ន្ធ |
|---|---|---|
| 1) ការគ្រប់គ្រងម៉ាស៊ីនបម្រើមូលដ្ឋានទិន្នន័យ | ការិយាល័យគ្រប់គ្រងទិន្នន័យ ឧបករណ៍ និង សម្ភារៈនៃនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ | — |

### 2.3.3 សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលអំពីការត្រួតពិនិត្យស្ពាន

វាពិតជាមានប្រយោជន៍ណាស់ក្នុងការចែកចាយព័ត៌មានអំពីចំណេះដឹង និងបច្ចេកវិទ្យាថ្មីៗ និង ទំនោរនៃការខូចខាត តាមរយៈសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ដែលធ្វើឡើងនៅទូទាំង ប្រទេស។ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលត្រូវធ្វើឡើងជាប្រចាំ ដើម្បីកសាងភាពជាដៃគូ និង បណ្តាញក្នុងចំណោមបុគ្គលិកនាយកដ្ឋានសាធារណការ និងដឹកជញ្ជូន។

បន្ថែមពីលើនេះទៀត វាគឺជាការល្អដែលយើងត្រូវបង្កើត និងលើកកម្ពស់យន្តការសម្រាប់ចែក ចាយព័ត៌មានក្នុងនាយកដ្ឋានសាធារណការ និងដឹកជញ្ជូននីមួយៗ។ អង្គភាពទទួលខុសត្រូវ និងដំណើរការនៃការរៀបចំមានដូចខាងក្រោម៖

1) **ការិយាល័យផែនការ និងបច្ចេកទេសសម្រាប់ផ្លូវថ្នល់ និងស្ពាននៃនាយកដ្ឋានសាធារណការ និងដឹកជញ្ជូន**មានទំនួលខុសត្រូវក្នុងការរៀបចំ និងធ្វើសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលថ្នាក់ ជាតិ។
2) វគ្គបណ្តុះបណ្តាលមូលដ្ឋាន និងការផ្សព្វផ្សាយព័ត៌មានត្រូវបានធ្វើឡើងដោយ**នាយករងនៃការិយាល័យសាធារណការនៃនាយកដ្ឋានសាធារណការ និងដឹកជញ្ជូន** និង**នាយករងនៃការិយាល័យនៃអង្គភាពផ្លូវថ្នល់ និងស្ពាននៃនាយកដ្ឋានសាធារណការ និងដឹកជញ្ជូន។**

**Table 2.3.9 អង្គភាពទទួលខុសត្រូវលើសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលស្តីអំពីការត្រួត ពិនិត្យស្ពាន**

| មាតិកា | អង្គភាពទទួលខុសត្រូវ | ផ្នែកពាក់ព័ន្ធ |
|---|---|---|
| 1) ការរៀបចំ និងការអនុវត្តសិក្ខាសាលា និងវគ្គ បណ្តុះបណ្តាលថ្នាក់ជាតិ | ការិយាល័យផែនការ និងបច្ចេកទេស សម្រាប់ផ្លូវថ្នល់ និងស្ពាននៃនាយកដ្ឋានហេដ្ឋារចនា សម្ព័ន្ធផ្លូវថ្នល់ | ក្រសួងសាធារណការ និងដឹកជញ្ជូន, នាយកដ្ឋានសាធារណការ និងដឹកជញ្ជូន |
| 2) ធ្វើសិក្ខាសាលាមូលដ្ឋាន និង ផ្សព្វផ្សាយព័ត៌មាន | នាយករងនៃការិយាល័យសាធារណការនៃនាយកដ្ឋានសាធារណការ និង ដឹកជញ្ជូន និងនាយករងនៃការិយាល័យនៃអង្គភាពផ្លូវថ្នល់ និងស្ពាននៃនាយកដ្ឋានសាធារណការ និងដឹកជញ្ជូន។ | នាយកដ្ឋានសាធារណការ និងដឹកជញ្ជូន |

# ជំពូកទី 3 សុវត្ថិភាព និងការងារថែទាំ

## 3.1 ការរក្សាសុវត្ថិភាពសម្រាប់ការងារជួសជុល

### 3.1.1 ការណែនាំពីការងារសុវត្ថិភាព

ការដ្ឋានសាងសង់តែងតែប្រឈមមុខនឹងហានិភ័យចំពោះជីវិត បើប្រៀបធៀបទៅនឹងឧស្សាហកម្មដទៃទៀត។ **Fig.3.1.1.1** បង្ហាញពីអត្រាគ្រោះថ្នាក់នៃការងារសាងសង់សម្រាប់ឧស្សាហកម្មទាំងអស់ក្នុងប្រទេសជប៉ុន។ ទោះបីជាអត្រាគ្រោះថ្នាក់នៃការងារសាងសង់មានប្រហែល15% ក្នុងគ្រោះថ្នាក់ទាំងអស់ (ទាំងការរងរបួស និងមរណៈភាព) វាមានគ្រោះថ្នាក់ធ្ងន់ធ្ងរ និងគ្រោះថ្នាក់ច្រើនជាងពាក់កណ្តាលត្រូវបានបង្កឡើងដោយការសាងសង់។ ដោយសារតែហេតុនេះហើយ វាគួរតែប្រុងប្រយ័ត្នឲ្យបានខ្ពស់បំផុតចំពោះគ្រោះថ្នាក់ណាមួយដែលបង្កដោយយថាហេតុពីវិស័យសំណង់។ វាពិតជាមានសារៈសំខាន់ណាស់ ក្នុងការគិតគូរសុវត្ថិភាពសម្រាប់កម្មករ មិនត្រឹមតែក្នុងអំឡុងពេលជួសជុលប៉ុណ្ណោះទេ តែក៏ចំពោះមុនពេលដែលចាប់ផ្តើមការងារសាងសង់ផងដែរ។ បន្ថែមទៅលើការយល់ដឹងរបស់អ្នកត្រួតពិនិត្យ វាក៏មានសារៈសំខាន់ផងដែរក្នុងការចែករំលែករវាង ការអប់រំកម្មករដែលធ្វើការពីគ្រោះថ្នាក់នៃការងារជួសជុល និងវិធានការសុវត្ថិភាព។




Fig 3.1.1.1 ទិន្នន័យគ្រោះថ្នាក់ក្នុងឧស្សាហកម្មទាំងអស់ (ក្នុងប្រទេសជប៉ុន)

**Fig 3.1.1.2** បង្ហាញពីទំហំមរណៈភាពដែលបង្កឡើងក្នុងការដ្ឋានសាងសង់ក្នុងប្រទេសជប៉ុន។ “ការធ្លាក់” និង “គ្រោះថ្នាក់ចរាចរណ៍” គឺជាកត្តាចម្បងនៃមរណៈភាព។ គ្រោះថ្នាក់ដោយការធ្លាក់ក្នុងការដ្ឋានសាងសង់ តែងតែកើតឡើងពេលដែលកម្មករនៅកន្លែងដែលខ្ពស់ (**Photo 3.1.1.1**) ឬក៏ពេលដែលកម្មករធ្វើការឆ្លងកាត់ទីតាំងក្បែរនៅលើស្ពាន (**Photo 3.1.1.2**) ពេលដែលត្រូវការរន្ធា ក្តារជាន់មិនត្រូវមានចន្លោះប្រហោងធំពេកនោះទេ (**Photo3.1.1.3**)។ បន្ថែមពីនេះទៅទៀត បង្កាន់ដៃសុវត្ថិភាពគួរតែតំឡើងសម្រាប់ការពារការធ្លាក់ (**Fig.3.1.1.3**)។ ហើយប្រសិនជាអាចទៅរួច វាមានភាពចាំបាច់ក្នុងការផ្តល់នូវវិធានការសុវត្ថិភាពសម្រាប់ការឆ្លងកាត់ស្ពានមានភាពងាយស្រួល ដូចជាកាំជណ្តើរបណ្តោះអាសន្នក្រោមស្ពាន (**Photo 3.1.1.2**) ឬក៏ការសម្អាតគុម្ពស្មៅជុំវិញស្ពានក្នុងពេលថៃទាំជាប្រចាំ (ការសម្អាត)។




**Fig 3.1.1.2 អត្រាគ្រោះថ្នាក់ដល់ស្លាប់ (ក្នុងប្រទេសជប៉ុន)**




**Photo 3.1.1.1 ការងារនៅកន្លែងខ្ពស់**




**Photo 3.1.1.2 ផ្លូវចុះចំណោទ**




**(a) ទីតាំងការងារមានប្រហោង**




**(b) បង្កាន់ដៃរន្ទា**

**Photo 3.1.1.3 រន្ទា**

គ្រោះថ្នាក់ចរាចរណ៍បង្កឲ្យមានមរណៈភាព តែងតែកើតឡើងក្នុងការងារជួសជុល ជាជាងការងារសាងសង់ ដោយសារតែការងារជួសជុលតែងតែធ្វើឡើងក្បែរនឹងចរាចរឆ្លងកាត់ (**Photo 3.1.1.4**)។ សម្រាប់វិធានការការពារនៃការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ វាមានប្រសិទ្ធិភាពក្នុងការដាក់ស្លាកសញ្ញា “ការដ្ឋាននៅខាងមុខ” នៅលើផ្លូវជាការប្រុងប្រយ័ត្នបន្ថែមទៀតសម្រាប់អ្នកបើកបរ (**Photo 3.1.1.5**)។



Photo 3.1.1.4 ផ្លូវធ្វើដំណើរ




Photo 3.1.1.5 ស្លាកសញ្ញាការដ្ឋាន

ដូចនេះហើយ គ្រោះថ្នាក់អាចកាត់បន្ថយបានជាកម្រិត ប្រសិនជាវិធានការសុវត្ថិភាពត្រឹមត្រូវ ត្រូវបានរៀបចំជាមុន និងធ្វើឡើងក្នុងអំឡុងពេលសាងសង់។ គ្រោះថ្នាក់ក៏អាចកើតឡើងផងដែរនៅពេលដែលកម្មករទម្លាប់និងការងារ និងចាប់ផ្តើមបាត់បង់ស្មារតីប្រុងប្រយ័ត្ន។ អ្នកត្រួតពិនិត្យមិនគួរធ្វេសប្រហែស ហើយត្រូវរក្សាការប្រុងប្រយ័ត្នជានិច្ច ទោះបីជាមិនមានគ្រោះថ្នាក់កើតឡើងក៏ដោយ។

វាមានសារៈសំខាន់ដែលការងារជួសជុល គួរតែអនុវត្តតាមលក្ខខណ្ឌការងារចំពោះកម្មករ គឺត្រូវបានធានាទាំងស្រុង។
ប្រសិនជាសុវត្ថិភាពរបស់កម្មករមិនអាចធានាបាន គ្រប់ការងារទាំងអស់ មិនត្រូវចុះអនុវត្តឡើយ។

### 3.1.2 ការបញ្ជាក់មុនចាប់ផ្តើមការងារជួសជុល

មុននឹងការងារជួសជុលត្រូវបានចាប់ផ្តើម វាមានសារៈសំខាន់ក្នុងការត្រួតពិនិត្យការដ្ឋាន (**Photo 3.1.2.1**) ដើម្បីបញ្ជាក់ពី គោលដៅខូចខាត ដែលត្រូវធ្វើការជួសជុល (ការធ្វើតារាងត្រួតពិនិត្យ (**Fig.3.1.2.1**)) ហើយរបៀបដែលឆ្លងកាត់ទៅកន្លែងដែលខូចខាតនោះ។ ដោយផ្អែកទៅលើការត្រួតពិនិត្យការដ្ឋាន ត្រូវរៀបចំបរិក្ខារបណ្តោះអាសន្ន ដូចជា រន្ទា តារាងកាលវិភាគការងារ សំភារៈ និងវត្ថុធាតុ។ ស្របជាមួយគ្នានេះដែរ វាមានសារៈសំខាន់ក្នុងការរៀបចំការគ្រប់គ្រងសុវត្ថិភាព ក្នុងអំឡុងពេលអនុវត្ត។



**Photo 3.1.2.1** ត្រួតពិនិត្យទីតាំង (មុនពេលការងារជួសជុល)




**Fig 3.1.2.1** ឯកសារត្រួតពិនិត្យ

បន្ទាប់ពីបានត្រួតពិនិត្យការដ្ឋាន ដើម្បីចែករំលែកចំណេះដឹងពីដំណាក់កាលការងារ និងពត៌មានដែលទាក់ទង រវាងអ្នកចូលរួម គួរតែបើកការប្រជុំជាបឋមមន្ត្រីអនុវត្តការងារ (**Photo 3.1.2.2**)។ ក្នុងការប្រជុំនេះ ដំណាក់កាលការងារលម្អិត កាលវិភាគ វិធានការសុវត្ថិភាព ចំនួនកម្មករដែលបានបញ្ជូន វត្ថុធាតុ ឧបករណ៍ និងកិច្ចការនៃកម្មករម្នាក់ៗ ត្រូវបានពិភាក្សា និងបញ្ជាក់ ដោយផ្អែកទៅលើចំណេះដឹងដែលបានដឹងថ្មី ពីការត្រួតពិនិត្យការដ្ឋាន និងតារាងត្រួតពិនិ្យ (**Fig. 3.1.2.1**) ។



**Photo 3.1.2.2 ប្រជុំពីការងារជួសជុល** (**មុនពេលធ្វើការងារជួសជុល**)

ស្មៅ គុម្ពស្មៅ និងសំរាម នៅលើការដ្ឋានជួនកាលអាចបង្កឲ្យកម្មករ ជំពប់ជើង ឬក៏រអិល ហើយធ្វើឲ្យរន្ធាគ្មានលំនឹង។ ហើយសំរាមខ្លះបង្កប់នូវវត្ថុធាតុដែលមានគ្រោះថ្នាក់ទៀតផង ដូចជា អំបែងកែវ របស់ស្រួចៗ ម្ជុលជាដើម ហើយវត្ថុទាំងនេះអាចបង្កប់ក្រោមស្មៅ និងគុម្ពស្មៅ (**Photo 3.1.2.3**)។ ដូចនេះហើយ វាមានសារៈសំខាន់ណាស់ក្នុងការសម្អាតស្មៅ គុម្ពស្មៅ និងសំរាម មុននឹងចាប់ផ្តើមធ្វើការជួសជុល។(**Photo 3.1.2.4**) ដោយសារតែវាត្រូវការរយៈពេលគួរសមដែរសម្រាប់ការសម្អាតនិងយករបស់ទាំងនោះចេញ រយៈពេលនៃការសម្អាតនេះគួរតែបញ្ចូលក្នុងកាលវិភាគការងារជួសជុល ហើយក្នុងករណីខ្លះវាគួរតែធ្វើឲ្យបានរួចរាល់ក្នុងមួយថ្ងៃមុននឹងការងារជួសជុលចាប់ផ្តើម។



**Photo 3.1.2.3** វត្ថុគ្រោះថ្នាក់នៅការដ្ឋាន




**Fig 3.1.2.2** ក្រលុកដែលមើលមិនឃើញនៅក្នុងស្មៅ



**Photo 3.1.2.4** កាត់ស្មៅ

### 3.1.3 ការបញ្ជាក់ក្នុងអំឡុងពេលអនុវត្តការងារជួសជុល

រាល់បុគ្គលទាំងអស់ដែលចូលក្នុងការដ្ឋាន មិនមែនត្រឹមតែកម្មករទេ តែអ្នកត្រួតពិនិត្យផងដែរ ត្រូវតែពាក់ពួកការពារ (**Photo 3.1.3.1**) ស្បែកជើងធ្វើការ ឬក៏ស្បែកជើងស្បែក (**Photo 3.1.3.2**)។ ស្បែកជើងផ្ទាត់មិនត្រូវបានអនុញ្ញាតឲ្យពាក់ក្នុងការដ្ឋានទេ។ ស្រោមដៃការពារជ័រ (**Photo 3.1.3.3**) គួរតែពាក់ក្នុងករណីដែលប្រើប្រាស់វត្ថុធាតុមានគ្រោះថ្នាក់ដែលប៉ះពាល់ទៅលើស្បែក។



**Photo 3.1.3.1 មួកការពារ**



**(a) ស្បែកជើងធម្មតា** **(b) ស្បែកជើងការដ្ឋាន**

**Photo 3.1.3.2 ស្បែកជើងធម្មតា និងស្បែកជើងការដ្ឋាន**



**Photo 3.1.3.3 ស្រោមដៃ**

មុននឹងចាប់ផ្តើមការងារជួសជុល អ្នកត្រួតពិនិត្យត្រូវតែប្រជុំកម្មករទាំងអស់ ហើយបើកការប្រជុំមួយ ដើម្បីបញ្ជាក់ពីដំណាក់កាលការងារក្នុងមួយថ្ងៃ និងការប្រុងប្រយ័ត្នសម្រាប់សុវត្ថិភាព (**Photo 3.1.3.4**)។



**Photo 3.1.3.4 ជួបជុំគ្នានៅការដ្ឋានមុនពេលចាប់ផ្តើមការងារជួសជុល**

បន្ទាប់ពីការប្រជុំនៅការដ្ឋានរួចរាល់ សមាជិកទាំងអស់ត្រូវធ្វើការសម្អាតការដ្ឋានជាមុន ប្រសិនជាចាំបាច់ (**Photo 3.1.3.5**)។ ជាទូទៅ ការសម្អាតការដ្ឋានគួរតែធ្វើជារៀងរាល់ថ្ងៃ ដើម្បីរក្សាលក្ខណៈធ្វើការងារប្រកបដោយសុវត្ថិភាព។





**Photo 3.1.3.5 សំអាតការដ្ឋាន (ការងារជុសជុល)**

នៅដែលរន្ទាត្រូវបានតំឡើង ដីដែលនៅជុំវិញជើងរបស់រន្ទាគួរតែរាបស្មើ ឬក៏ប្រវែងនៃជើងនោះត្រូវតម្រូវ ដើម្បីធ្វើឲ្យក្ដារបន្ទះជាន់ត្រូវបានរក្សាក្នុងសភាពរាបស្មើ និងមានលំនឹង (**Photo 3.1.3.6**)។ បន្ទះការជាន់ត្រូវដាក់នឹងផ្អឹងដែកឲ្យបានជាប់ល្អ ហើយក្ដារបន្ទះជាន់ដែលមានកម្រិតខុសគ្នា គួរតែរក្សាឲ្យបានស្មើគ្នា ដើម្បីបង្ការហានិភ័យនៃការជំពប់ជើង ហើយធ្លាក់ (**Fig 3.1.3.1**)។




**Photo 3.1.3.6 រៀបចំរន្ទា**




**Fig 3.1.3.1 គ្រោះថ្នាក់បណ្តាលមកពីកម្ពស់មិនស្មើគ្នា**

ការងារជួសជុលត្រូវចាប់ផ្តើមបន្ទាប់ពីតំឡើងរន្ទា។ កម្មករត្រូវបានហាមឃាត់មិនឲ្យជក់បារីក្នុងការដ្ឋាន ពីព្រោះមានសារធាតុជួសជុលដែលងាយនឹងឆាបឆេះ។ អ្នកត្រួតពិនិត្យគួរតែត្រួតពិនិត្យសកម្មភាពរបស់កម្មករឲ្យបានប្រុងប្រយ័ត្ន ដើម្បីធានាបានថាពួកគេគោរពទៅតាមបទបញ្ញាសុវត្ថិភាពការងារ។

ការងារសម្រាប់មួយថ្ងៃត្រូវបញ្ចប់ ហើយអ្នកត្រួតពិនិត្យត្រូវអនុញ្ញាតឲ្យកម្មករឈប់បន្ទាប់ពីបានបញ្ជាក់ពីកិច្ចការសម្រាប់ថ្ងៃបន្ទាប់បានរួចរាល់។ គួរចងចាំថាកាកសំនល់ណាមួយដែលបង្កចេញពីការងារ គួរតែយកត្រលប់មកវិញ ដោយមិនត្រូវទុកចោលនៅការដ្ឋាននោះទេ។

យើងគួរតែប្រើប្រាស់ឧបករណ៍ជួសជុលដោយប្រុងប្រយ័ត្ន។ ហើយបន្ទាប់ពីបញ្ចប់ការងារជួសជុល ត្រូវតែធ្វើការសំអាតឧបករណ៍អោយបានស្អាត (ឧទាហរណ៍: ដោយប្រើប្រាស់ប្រេងកាត់ និងក្រដាសទន់) រួចរៀបចំទុកដាក់អោយបានល្អ (**Photo 3.1.3.7**).




**Photo 3.1.3.7 សំអាតនិងថែទាំឧបករណ៍ជួសជុល**

## 3.2 ការថែទាំប្រចាំ

### 3.2.1 គោលបំណងនៃការថែទាំប្រចាំ

ដើម្បីការពារភាពខូតខាតនៃរចនាសម្ព័ន្ធរបស់ស្ពាន ការងារសម្អាតគួរតែធ្វើឡើង ដោយរួមបញ្ចូលទាំងការសម្អាតវត្ថុធាតុមកពីប្រភពដទៃទាំងអស់ ពីទីតាំងទាំងមូលរបស់ស្ពាន ដូចជា កម្រាលស្ពាន ផ្លូវសម្រាប់ថ្មើរជើង ចញ្ចើមថ្នល់ សរសរខាងលើ ចន្ទល់ខ្វែង និងផ្នែកភ្ជាប់ ក្រចាប់តំណផ្នែកខាងក្រោមនៃធ្នឹម ឬក៏ឃ្នាប មុខតំណ ទ្រនាប់ដែកទប់ខ្យល់ និងបរិក្ខារបង្ហូរទឹក។ បន្ទាប់ពីសម្អាតរួច គួរតែធានាបានថាមិនមានដីខ្សាច់ ក្រួស ដី និងវត្ថុធាតុមកពីប្រភពផ្សេងនានានៅសេសសល់នៅលើទីតាំង។

ជាពិសេសបំពង់បង្ហូរទឹក ត្រូវតែសម្អាតជាប្រចាំ ដើម្បីជៀសវាងពីការសេសសល់ទឹកភ្លៀង ដែលជារឿយបណ្ដាលឲ្យមានការច្រេះចាប់លើផ្នែកនានានៃរចនាសម្ព័ន្ធ។

### 3.2.2 ការអនុវត្តលក្ខណៈវិនិច្ឆ័យ

ស្ពានត្រូវរក្សាឲ្យបានស្អាត និងក្នុងស្ថានភាពល្អ ដើម្បីពន្យារយៈពេលប្រើប្រាស់វាបានយូរ ហើយក៏ដូចជា ផ្តល់នូវសុវត្ថិភាព និងផាសុខភាព ទៅកាន់អ្នកប្រើប្រាស់ផ្លូវ។ អនុសាសន៍លក្ខណៈវិនិច្ឆ័យសម្រាប់ការសម្អាត ប្រើប្រាស់ទៅលើស្ពាន រួមមានផ្ទៃដែក កម្រាល និងរចនាសម្ព័ន្ធផ្នែកខាងក្រោម មានដូចខាងក្រោម៖

#### a) ប្លង់សេកម្រាលស្ពាន

ផ្នែកខាងលើទាំងអស់នៃកម្រាលស្ពាន គួរតែសម្អាត រួមមាន លូបង្ហូរទឹក យើប មុខតំណស្ពាន និង បង្កាន់ដៃ។ ការសម្អាតនេះអាចធ្វើឡើងបានដោយប្រើប្រាស់ការបាញ់សំពាធទឹកកម្រិតខ្ពស់ ឬក៏ការជីក/បោសសម្អាត ដោយដៃ។

#### b) រចនាសម្ព័ន្ធស្ពាន

ទីតាំងទាំងអស់ក្រោមរចនាសម្ព័ន្ធផ្នែកខាងក្រោមគួរតែសម្អាត រួមមាន កំណល់ស្ពាន ជញ្ជាំងបង្កាន់ដៃ ក្បាលសរសរ និងសន្ទះបេតុង។ ការសម្អាតនេះអាចធ្វើឡើងបានដោយប្រើប្រាស់ការបាញ់សំពាធទឹកកម្រិតខ្ពស់ ឬក៏ការជីក/បោសសម្អាតដោយដៃ។

#### c) ផ្ទៃនៃបន្ទះដែក

ទីតាំងទាំងអស់នៃស្ពានដែកគួរតែសម្អាត រួមមានផ្នែកខាងលើ និងខាងក្រោមនៃគែមក្រចាប់តំណ បន្ទះដែក សន្ទះផ្នែកសងខាង និងបន្ទះតំណ។ ការសម្អាតនេះគួរតែប្រើប្រាស់ការបាញ់សំពាធទឹកកម្រិតខ្ពស់។ យានយន្តត្រួតពិនិត្យត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាព ដើម្បីធ្វើការសម្អាតផ្នែកខាងក្រោមនៃទីតាំងខ្ពស់នៃស្ពាន។

### 3.2.3 លំដាប់លំដោយការងារ

#### a) ការសម្អាតកម្រាលស្ពាន និងប្រពន្ធ័បង្ហូរទឹកស្ពាន

រាល់វត្ថុធាតុមកពីប្រភពដទៃទាំងអស់ ដូចជាដី ធូលីដី ដីខ្សាច់ ទឹកភ្លៀង និងស្លែ នៅលើផ្ទៃបេតុងក្នុងចន្លោះរវាងឃើប ត្រូវយកចេញឲ្យអស់ដោយដៃ ហើយបន្ទាប់មកលាងសម្អាតដោយប្រើប្រាស់ការបាញ់សំពាធទឹកកម្រិតខ្ពស់។ ប្រពន្ធ័បង្ហូរទឹក និងមុខតំណស្ពាន នៅលើកម្រាលស្ពានគួរតែសម្អាតឲ្យបានប្រុងប្រយ័ត្នផងដែរ៖




**Photo 3.2.3.1 ស្ទះបំពង់បង្ហូរទឹក**



**Photo 3.2.3.2 តំណស្ពានស្ទះដោយខ្សាច់និងធូលី**



**Photo 3.2.3.3 សំអាតបំពង់បហ្វូរទឹកដោយការបាញ់ទឹក**



**Photo 3.2.3.4 សំអាតបំពង់បង្ហូរទឹក**

## b) ការសម្អាតរចនាសម្ព័ន្ធខាងក្រោមនៃស្ពាន

វត្ថុធាតុមកពីប្រភពដទៃទាំងអស់ ដូចជាដី ធូលីដី ដីខ្សាច់ ទឹកភ្លៀង និងស្លែនៅលើផ្ទៃក្បាលស្ពាន និងទម្រស្ពាន និងតំណទ្រនាប់សរសរ ត្រូវយកចេញឲ្យអស់ដោយដៃផងដែរ ហើយបន្ទាប់មកលាងសម្អាតដោយការបាញ់សំពាធទឹកកម្រិតខ្ពស់។ ភក់ និងដីខ្សាច់ ដែលមាននៅខាងនៃក្បាលស្ពាន ត្រូវសម្អាតចេញ ដើម្បីរក្សាចំងាយដើមរបស់វាពីច្រាំងទន្លេ។



**Photo 3.2.3.5 មានដុះរុក្ខជាតិលើស្ពាន**



**Photo 3.2.3.6 មានភក់ កំទេចកំទី ខ្សាច់នៅទម្រស្ពាន**



**Photo 3.2.3.7** សំអាតទម្រស្ពាន



**Fig. 3.2.3.1** សំអាតស្មៅនិងរុក្ខជាតិនៅជិតស្ពាន

# ជំពូកទី 4 ចន្លោះសម្រាប់ធ្វើការថែទាំ និងចំណេះដឹងមូលដ្ឋានពីបេតុង

## 4.1 ចន្លោះសម្រាប់ធ្វើការថែទាំ

មិនថាសម្រាប់រចនាសម្ព័ន្ធស្ពានបែបណានោះទេ វាត្រូវបានផ្តល់ដំបូន្មានថារក្សាចន្លោះសមស្របសម្រាប់ធ្វើការងារថែទាំ ផ្នែកទាំងសងខាង និងក្រោមឃ្នាប ដើម្បីធ្វើការតំឡើងរន្ធាបានត្រឹមត្រូវ។លើកលែងចំពោះស្ពានមានចន្លោះវែង ស្ពានបេតុងជាទូទៅមានចន្លោះខ្លី ហើយតូចរវាងឃ្នាប។ហើយមានឃ្នាបពង្រឹកតូច ដែលផ្តល់ចន្លោះ និងទ្រនូវបន្ទុករចនាសម្ព័ន្ធផ្នែកខាងក្រោម មានទំហំតូច ជាទូទៅមុនតំណ និងទ្រនាប់ដែលមានទំហំតូចត្រូវបានប្រើប្រាស់។ ដោយសារមូលហេតុនេះហើយទើបមានចន្លោះតិចសម្រាប់ធ្វើការថែទាំសរសរខាងលើ និងធ្វើឲ្យការត្រួតពិនិត្យ និងជួសជុលមានភាពលំបាក។

ដូចនេះហើយ ទោះបីជារចនាសម្ព័ន្ធបេតុងក៏ដោយ វាមានភាពចាំបាច់ក្នុងការធានាចន្លោះសម្រាប់ធ្វើការថែទាំគ្រប់គ្រាន់ (ចន្លោះសម្រាប់ធ្វើការងារ និងផ្សេងៗ) ដូចដែលបានចែងនៅទីនេះ។

ចន្លោះធ្វើការថែទាំបានគ្រប់គ្រាន់ គួរតែធានាបានសម្រាប់រចនាសម្ព័ន្ធដូចខាងក្រោម (**Photo 4.1.1**) ។

(a) រចនាសម្ព័ន្ធស្ពាននៅលើទន្លេ និងផ្លូវទឹក

(b) រចនាសម្ព័ន្ធស្ពាននៅលើផ្លូវឆ្លងកាត់

(c) រចនាសម្ព័ន្ធស្ពាននៅជិតរចនាសម្ព័ន្ធដែលគ្មានចលនា។



**(a) លើទឹក**



**(b) លើផ្លូវ**

**Photo 4.1.1 ទីតាំងថែទាំមានកម្រិត**

រំពឹងថានឹងមានតម្រូវការត្រួតពិនិត្យ ជួសជុល និងកែលម្អដោយសារសំនឹកនាពេលអនាគត ដែលបណ្តាលមកពីអាយុកាល និងករណីដែលកើតឡើងដោយមិនអាចគិតទុកមុន នៅក្នុងដំណាក់កាលរៀបចំ និងរចនា រចនាសម្ព័ន្ធស្ពាននានាត្រូវបានផ្តល់ដំបូន្មានឲ្យរក្សាចន្លោះសម្រាប់ធ្វើការថែទាំគ្រប់គ្រាន់ នៅជុំវិញរចនាសម្ព័ន្ធចម្បង។ ចន្លោះសម្រាប់ធ្វើការថែទាំរួមមាន ចន្លោះសម្រាប់រន្ទានៅលើផ្នែកទាំងសងខាង និងក្រោមឃ្នាប ចន្លោះធ្វើការងារត្រួតពិនិត្យ ជួសជុល និងកែលម្អ និងចន្លោះណាមួយដែលមានអាចមានភាពចំបាច់នាពេលអនាគត។ រន្ទាត្រូវការចន្លោះគ្រប់គ្រាន់ផងដែរសម្រាប់ដាក់ឧបករណ៍ពង្រីក ផ្លូវសម្រាប់កម្មករដើរ និងជណ្តើរ និងបង្កាន់ដៃការពារ។ ឧទាហរណ៍ចន្លោះសម្រាប់ធ្វើការថែទាំត្រូវបានបង្ហាញក្នុង **Fig. 4.1.1** និង **Table 4.1.1**




**Fig. 4.1.1 ស្តង់ដារក្នុងការរៀបចំរន្ទា**



**Photo 4.1.1 ការដាក់រន្ទា**

**Table 4.1.1 ស្តង់ដារចន្លោះសំរាប់ការងារជួសជុលស្ពាន**

<table>
<tr><td>ចន្លោះសម្រាប់ធ្វើការថែទាំក្រោមឃ្នាប</td><td>
</td></tr>
<tr><td>ចន្លោះសម្រាប់ធ្វើការថែទាំក្រោមសរសរឃ្នាប</td><td>
</td></tr>
<tr><td>ការលម្អិតពីចន្លោះសម្រាប់ធ្វើការថែទាំ</td><td>
</td></tr>
</table>

**Table 4.1.2** ប្រៀបធៀបទីតាំងរបស់កម្មករ និងកម្រិតនឿយហត់ដែលជាប់ទាក់ទង ក្នុងអំឡុងពេលធ្វើការថែទាំ។ នៅពេលដែលកម្មករធ្វើការនៅផ្នែកខាងក្រោមនៃក្រចាប់តំណខាងក្រោមនៃឃ្នាបធំក្បែរនឹងទ្រនាប់ កម្រិតនៃភាពនឿយហត់របស់គាត់/នាង អាចកើនឡើងទ្វេដង។ កន្លែងធ្វើការងារគ្រប់គ្រាន់ គួរតែផ្តល់តាមតែអាចធ្វើទៅបាន ដើម្បីឲ្យកម្មករអាចធ្វើការងារ និងធ្វើចលនាដោយគ្មានការបង្អាក់រាងកាយ។

ដូចដែលបានបង្ហាញក្នុង **Fig 4.1.2** ក្នុងករណីដែលរចនាសម្ព័ន្ធទ្រនាប់ជាមួយនឹងផ្លូវផ្សេងទៀត ចន្លោះគ្រប់គ្រាន់រវាង វិធីត្រឹមត្រូវ នៃផ្លូវស្រប និងសរសរឃ្នាបដែលជាប់គ្នា និងសរសរ ជាទូទៅគួរតែរក្សាសម្រាប់ចន្លោះសម្រាប់ធ្វើការថែទាំ។




**Fig. 4.1.2 ទំហំតូចបំផុតសំរាប់ទីតាំងការងារជួសជុលតាមផ្នែក**

**Table 4.1.2 ឥរិយាបទការងារ និងសម្ថតភាពការងារ**

| | | ឥរិយាបទការងារ | | | ចន្លោះដែលត្រូវការ (ទំហំស្តង់ដា) :m | | | ភាពនឿយហត់ (យោង) | ឥរិយាបទសម្រាក | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ឥរិយាបទ | គំនូរ | | | | | | | | |
| | | | មើលពីចំហៀង | មើលពីខាងមុខ | កម្ពស់ | ទទឹង | ប្រវែង | ស្តង់ដា | ខ្លី | មធ្យម | វែង |
| 1 | ឈរ | ធ្វើការងារដោយសេរីដោយគ្មានការកំណត់ |  |  | 1.8 | 0.8 | 1.0 | 1.0 | សេរី | | |
| 2 | ចំកោង | មិនអាចធ្វើការងារបានទេ លុះត្រាតែកោងខ្នងបន្តិច |  |  | 1.5 | 0.8 | 1.0 | 1.5 | អង្គុយច្រហោង | | អង្គុយ |
| 3 | អង្គុយច្រហោង | មិនអាចធ្វើការងារបានទេ លុះត្រាតែអង្គុយច្រហោង |  |  | 1.2 | 0.8 | 1.0 | 1.2 | អង្គុយច្រហោង | | អង្គុយ |
| 4 | លុតជង្គង់ ឬក៏អង្គុយ | មិនអាចធ្វើការងារបាន លុះត្រាតែលុតជង្គង់ ឬក៏អង្គុយ |  |  | 1.0 | 1.0 | 1.0 | 1.1 | អង្គុយលើកៅអី | លាតជើង | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 5 | | មិនអាចធ្វើការងារបាន លុះត្រាតែគេងផ្កាប់មុខ ឬក៏ផ្ងារមុខ និងលាត ឬក៏បត់បែនរាងកាយផ្នែកខាងក្រោម |  |  | គេងរាបស្មើ > 0.6<br>គេងផ្ងារ > 0.6 | 0.8 | 1.6 | 2.0 | គេងរាបលើឥដ្ឋ | គេង ផ្ងារ |
| 6 | គេងរាប ស្មើ | មិនអាចធ្វើការងារបាន លុះត្រាតែ គេងចំហៀង និងលាត ឬក៏បត់បែនរាងកាយផ្នែកខាងក្រោម |  |  | 0.7 | 0.8 | 1.8 | 2.5 | គេងផ្ងារ | |
| 7 | | ធ្វើការងារក្នុងឥរិយាបទដែលពិបាកបំផុត ដោយគេងផ្កាប់មុខ ជាមួយនឹងដៃ និងក្បាលពោះនៅលើឥដ្ឋ ឬក៏គេងផ្ងារមុខឡើង |  |  | 0.4 | 0.8 | 1.8 | 2.5 | គេងផ្ងារ | |

ចំណាំ៖

1. ក្នុងចន្លោះឥរិយាបទសម្រាក ខ្លី មធ្យម និងវែង សំដៅទៅលើការសម្រាករយៈពេលខ្លី ការសម្រាករយៈពេលមធ្យម និងការសម្រាករយៈពេលវែង
2. ការសម្រាកមានន័យថាការឈប់សម្រាកនៅកន្លែងដដែល ដែលមានភាពខុសគ្នាពីការសម្រាកញុំកាហ្វេ ឬក៏ស្ថានភាពស្រដៀងនេះ

## 4.2 វត្ថុធាតុបេតុង

### 4.2.1 សមាសធាតុនៃបេតុង

បេតុងគឺជាការផ្សំឡើងពី ស៊ីម៉ង់ ទឹក គ្រួសម៉ត់ គ្រួសធំ និងសារធាតុផ្សំ **(Fig. 4.2.1)** ។ គ្រួសធំមានចំណែកធំជាងគេ ក្នុងទំហំនៃគួប ដែលបន្ទាប់មកមាន គ្រួសម៉ត់ ទឹក ស៊ីម៉ង់ និងសារធាតុលាយជាបន្តបន្ទាប់។




**Fig. 4.2.1 សមាសភាពនៃបេតុង**




**Fig.4.2.2 ប្រៀបធៀបសមាសភាពក្នុងការលាយផ្សេងៗគ្នា**

### 4.2.2 គ្រួស

សមាសធាតុដីខ្សាច់ ឬក៏គ្រួសតូច នៃវត្ថុធាតុបេតុង គឺជាទូទៅត្រូវបានហៅថា គ្រួស។ គ្រួសត្រូវបានបែងចែកជាគ្រួសដុំ និងម៉ត់ ដោយទំហំនីមួយៗ។ គ្រួសដុំគឺជាគ្រួសតូចដែលមានម៉ាសចំនួន 85% នៃទំហំទម្ងន់ ដែលអាចសល់នៅលើកន្ត្រងសួល 5mm (ស្មើនឹងគ្រួសតូចលើ៥ ម.ម ក្នុងទំហំ)។ គ្រួសម៉ត់គឺម៉ាសនៃដីខ្សាច់ ដែលឆ្លងកាត់កន្ត្រងលួស 10mm និងមាន85% នៃទំហំទម្ងន់ ដែលឆ្លងកាត់កន្ត្រងលួស 5mm។ ដោយសារតែទំហំនៃគូបសរុបនៃគ្រួស មានបេតុងប្រមាណជា70% គុណភាពរបស់វាមានផលប៉ះពាល់យ៉ាងធំទៅលើសមត្ថភាពនៃបេតុងទាំងមូល។



(a) គ្រួសគ្រាប់ធំៗ



(b) គ្រួសម៉ដ្ឋ

**Photo 4.2.1 គ្រឿងផ្សំ**

### 4.2.3 ស៊ីម៉ង់

ស៊ីម៉ង់គឺជាសមាសធាតុបេតុងដែលមានពណ៌ប្រផេះ និងមានសន្ទានជាម្សៅ ហើយធ្វើឲ្យរឹងដោយទឹក និងប៉ូលីម៉ែរ នៅពេលដែលលាយជាមួយនឹងទឹក ឬក៏វត្ថុធាតុរាវ។ ស៊ីម៉ង់ត្រូវបានបែងចែកជាបីប្រភេទ៖ ស៊ីម៉ង់ portland ស៊ីម៉ងលាយ និងស៊ីម៉ង់ពិសេស។ ជាទូទៅស៊ីម៉ង់ portland គឺត្រូវបានប្រើប្រាស់សម្រាប់បេតុងធម្មតា។

## 4.3 ការខូចខាតបណ្ដាលមកពីកំហុសសាងសង់

រចនាសម្ព័ន្ធបេតុងត្រូវការភាពរឹងមាំ ភាពធន់ ការការពារទឹក និងរូបរាងពីខាងក្រៅជាក់លាក់ ដោយយោងទៅតាមគោលបំណងប្រើប្រាស់។ នៅពេលដែលសាងសង់ ការធ្វើដោយប្រុងប្រយ័ត្នត្រូវតែធ្វើឲ្យបានទៅតាមគុណភាពដែលតម្រូវឲ្យធ្វើតាម។

ទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែបេតុងមានភាពស្មុគស្មាញក្នុងការលាយស៊ីម៉ង់ គ្រួស និងទឹក វាងាយនឹងមានការហៀរចេញជាមួយនឹងការធ្វើការលាយ ដឹកជញ្ជូន និងចាក់មិនបានល្អ។ម្យ៉ាងទៀត ភាពរឹងមាំតូចៗនៃបេតុងនាំឲ្យមានស្នាមប្រេះ ដោយសារតែការសាងសង់មិនបានត្រឹមត្រូវ។

កំហុស និងស្នាមប្រេះក្នុងដំណាក់កាលសាងសង់ទាំងនេះ អាចបង្កឲ្យមានបញ្ហាទៅលើ ភាពរឹងមាំ ភាពធន់ ការការពារទឹក និងរូបរាងពីខាងក្រៅ នៃផលិតផលចុងក្រោយ ការគ្រប់គ្រងប្រកបដោយការប្រុងប្រយ័ត្ន និងគុណភាពត្រឹមត្រូវ គឺមានភាពចាំបាច់ក្នុងដំណាក់កាលនេះ។ កំហុលទូទៅ និងប្រតិវិធានការ ត្រូវបានបង្ហាញដូចខាងក្រោម (**Fig. 4.3.1**)




**Fig. 4.3.1 លក្ខណៈខូចខាតនៃសំណង់និងមូលហេតុរបស់ពួកវា**

## 4.3.1 ការផ្លុះសុល និងប្រហោង

ដោយសារតែបេតុងថ្មី ស្ថិតក្នុងលក្ខខណ្ឌមួយ ដែលវត្ថុធាតុជាមួយនឹងទម្ងន់ជាក់លាក់ដែលខុសគ្នាៗ ដូចជាស៊ីម៉ង់ និងគ្រួសត្រូវបានលាយក្នុងទឹក ការលាយមិនបានស្មើសាច់ និងផលវិបាកដែលបណ្តាលមកពីកំហុលនៃការហៀរចេញ អាចកើតឡើងដោយការលាយ និងចាក់មិនបានល្អ។ ការហៀរចេញគឺជាបាតុភូតដែលផ្នែកមួយនៃសមាសធាតុទឹកគឺផ្តោតទៅលើ ផ្ទៃជាមួយនឹងការបង្កកគ្រួស និងធាតុល្អិតៗនៃស៊ីម៉ង់។

ពេលដែលមានការហៀរចេញកើតឡើង និងគ្រួសដុំធំ ផ្តុំមិនស្មើសាច់គ្នា ដោយគ្មានការលាយបាយអរគ្រប់គ្រាន់ ផ្នែកជាមួយនឹងចន្លោះតូចៗជាច្រើនអាចកើតចេញឡើង។ កំហុសនេះ ជាdធម្មតាត្រូវបានគេហៅថា ការផ្លុះសុល។ ម្យ៉ាងវិញទៀតពេលដែលមានការធ្វើបេតុងមិនបានល្អ ជាមួយនឹងការឆ្អឹងដែកច្រើនពេក ចន្លោះធំៗ ឬក៏ប្រហោងងាយនឹងកើតមាន ជាមួយនឹងការបង្ហាប់មិនបានល្អ។

ការផ្លុះសុល និងប្រហោង មិនត្រឹមតែបង្កឲ្យរបរាងពីខាងក្រៅអន់ប៉ុណ្ណោះទេ តែក៏ធ្វើឲ្យមានភាពខូចខាតធ្ងន់ធ្ងរផងដែរ ទៅលើភាពធន់ និងការការពារទឹក។ នៅពេលដែលមានការបាត់បង់ផ្នែកណាមួយ ភាពរឹងមាំនៃរចនាសម្ព័ន្ធក៏អាចកាត់បន្ថយផងដែរ។



**Photo 4.3.1 ផ្លុះសុល**

### (1) មូលហេតុបង្កឲ្យមានការផ្លុះសុល និងប្រហោង

ការផ្លុះសុល និងប្រហោងអាចនឹងកើតមានឡើង នៅពេលដែលធ្វើការចាក់បេតុងសម្រាប់ផ្នែកដែលត្រូវការណាមួយ មិនបានត្រឹមត្រូវ។

1) ប្លង់ការលាយស៊ីម៉ង់

នៅពេលដែលសមាមាត្រគ្រួស ទល់នឹងស៊ីម៉ង់ ខ្ពស់ជាងការលាយធម្មតា សមាសធាតុស៊ីម៉ង់មិនអាចទៅដល់ផ្នែកទាំងមូល ហើយការផ្លុះសុលអាចកើតឡើង។

2) ការបង្ហាប់បេតុងមិនបានល្អ

នៅពេលដែលបេតុងត្រូវបានចាក់ នៅផ្នែកណាមួយដែលម៉ាស៊ីនបង្ហាប់មិនអាចយកទៅដល់ ឬក៏ឆ្អឹងដែក ត្រូវបានដាក់ផ្តុំគ្នាច្រើនក្នុងចន្លោះតូចមួយ បេតុងមិនអាចចូលបានសព្វទាំងមូល ហើយការផ្លុះសុល ឬក៏ប្រហោងអាចនឹងកើតមានឡើង។

3) ទីតាំងចាក់បេតុងខ្ពស់

រចនាសម្ព័ន្ធ ដូចជាជញ្ជាំង និងសសរសរខ្ពស់ ដែលបេតុងថ្មីៗត្រូវតែចាក់ពីទីតាំងខ្ពស់ វាប៉ះពាល់ជាមួយនឹងពុម្ព និងឆ្អឹងដែក ហើយការហៀរចេញ អាចនឹងកើតមានឡើង។

## (2) វិធីសាស្ត្រជៀសវាង

ការធ្វើការប្លង់លាយបានត្រឹមត្រូវ ផ្អែកលើការកំណត់ជាក់លាក់នៃស្តង់ដារ គឺជាគន្លឹះក្នុងការជៀសវាងពីការបង្កើតឲ្យមានប្រហោង។ ម្យ៉ាងទៀតការចាក់បេតុងបានត្រឹមត្រូវ គួរតែត្រូវបានជ្រើសរើសដោយការគិតគូរពីទំហំ និងរូបរាងនៃផ្នែកដែលឆ្លងកាត់គ្នា និងការរៀបចំឆ្អឹងដែក នៅពេលដែលបេតុង គួរតែចាក់ និងបង្ហាប់ជាមួយនឹងការផែនការដែលបានពិសោធន៍យ៉ាងត្រឹមត្រូវ។នៅពេលដែលពុម្ពនៅខ្ពស់ ប្រហោងចាក់ក្នុងកម្ពស់មធ្យម និងឧបករណ៍ជំនួយដល់ការចាក់ ដូចជាឡានបាញ់ បូម ឬក៏ចាក់បេតុង គួរតែផ្តល់ឲ្យ។

### 4.3.2 ពងទឹក និង ស្នាមខ្សាច់

ទោះបីជាពងទឹក និងស្នាមដីខ្សាច់ មិនមែនជាបញ្ហាទៅលើរចនាសម្ព័ន្ធ ប៉ុន្តែពងទឹក និងស្នាមខ្សាច់មិនអាចទទួលយកបានទេ នៅពេលដែលរូបរាងពីខាងក្រៅត្រូវបានគិតគូរ។

#### (1) មូលហេតុបង្កឲ្យមានពងទឹក និងស្នាមដីខ្សាច់

នៅពេលដែលមានការហៀរចេញកើតឡើង ហើយទឹកនៅដក់តាមបន្ទះពុម្ព ប្រហោងពងទឹកកើតឡើងនៅលើផ្ទៃបេតុងបន្ទាប់ពីស្ងួត។ ស្នាមដីខ្សាច់ គឺជាបាតុភូតដែលទឹកបាននាំយកសមាសធាតុស៊ីម៉ង់ចេញ ហើយគ្រួសម៉ត់បានលេចឡើងនៅខាងលើផ្ទៃ។

#### (2) វិធីសាស្ត្រជៀសវាង

ដើម្បីជៀសវាង ឬក៏កាត់បន្ថយ ពងទឹក ឬក៏ស្នាមដីខ្សាច់ កើតឡើងដោយសារការហៀរចេញ គួរតែប្រើប្រាស់ការចាក់បេតុងឲ្យបានល្អ ហើយកម្ពស់នៃការចាក់ម្តងគួរតែតិចជាង 40-50 cm ជាមួយនឹងការបង្ហាប់បានល្អ។



**Photo 4.3.2 ស្នាមខ្សាច់**

### 4.3.3 ស្នាមប្រេះ

បេតុងដែលមានស្នាមប្រេះបណ្តាលឲ្យមានផលប៉ះពាល់អាក្រក់ទៅលើ ភាពរឹងមាំ ភាពធន់ ការការពារទឹក និងរូបរាងពីខាងក្រៅនៃរចនាសម្ព័ន្ធ។ ស្នាមប្រេះកើតឡើងដោយ ការបង្កចម្បងទាំងបួនប្រភេទដូចខាងក្រោម៖

(1) ទាក់ទងនឹងប្រតិបត្តិការណ៍នៃការសាងសង់

(2) ទាក់ទងនឹងលក្ខណៈនៃវត្ថុធាតុបេតុង

(3) ទាក់ទងនឹងស្ថានភាពប្រើប្រាស់ និងបរិស្ថានជុំវិញ

(4) ទាក់ទងនឹងលក្ខណៈនៃរចនាសម្ព័ន្ធ និងការទទួលបន្ទុក

**Table 4.3.1** បានបង្ហាញពីមូលហេតុបង្ក ដែលបានចាត់ថ្នាក់ទៅតាមប្រភេទដែលបានរៀបរាប់ពីខាងលើ។ តាមពិតទៅ ស្នាមប្រេះភាគច្រើន កើតឡើងដោយសារតែមូលហេតុបង្កឡើងជាច្រើនលាយចូលគ្នា។

**Table 4.3.1 ប្រភេទនៃមូលហេតុដែលបណ្តាលអោយប្រេះ**

| ចំណាត់ថ្នាក់ | | | មូលហេតុបង្ក |
|---|---|---|---|
| ការអនុវត្តន៍ | សារធាតុលាយបេតុង | ការងារលាយ | ការញែករត្ថុធាតុមិនស្មើគ្នា |
| | | | ការលាយមានរយៈពេលយូរ |
| | | ការដឹកជញ្ជូន | ការផ្លាស់ប្តូរផែនការលាយពេលបូម |
| | | ការចាក់ | ដំណាក់កាលនៃការចាក់មិនត្រឹមត្រូវ |
| | | | ការចាក់ប្រញាប់ប្រញាល់ពេក |
| | | ការបង្ហាប់ | ការបង្ហាប់មិនត្រឹមត្រូវ |
| | | ការកែតម្រូវ | រំញ័រ/បន្ទុកមុនពេលរឹង |
| | | | សម្ងួតលឿនពេកក្នុងដំណាក់កាលដំបូង |
| | | | កកពេលដែលធ្វើការកែតម្រូវ |
| | | ការចាក់តំណ | ការចាក់តំណមិនបានត្រឹមត្រូវ |
| | ឆ្អឹងដែក | ការដាក់សរសៃដែក | ការដាក់នៅចន្លោះដោយការស្មាន |
| | | | ជម្រៅគ្រប់ដណ្តប់មិនល្អ |
| | ពុម្ព | ឈើបន្ទះពុម្ព | ប៉ោង |
| | | | លេចទឹក |
| | | | ដកចេញមុនពេលបេតុងរឹង |
| | | ជន្ទល់ | ជន្ទល់ធ្លាក់ |

| | | | |
|---|---|---|---|
| វត្ថុធាតុ | សមាសធាតុវត្ថុធាតុ | ស៊ីម៉ង់ | រឹងខុសពីធម្មតា |
| | | | មានវត្ថុមានផ្សំនឹងទឹក |
| | | | ប៉ោងខុសពីធម្មតា |
| | | គ្រួស | មានសមាសធាតុដីឥដ្ឋក្នុងគ្រួស |
| | | | ប្រើប្រាស់គ្រួសគុណភាពអន់ |
| | | | ប្រតិកម្មស៊ីលីកា |
| | បេតុងថ្មីៗ | | ក្លរក្នុងបេតុង |
| | | | វត្ថុធាតុកក ការហៀរចេញ |
| | | | បេតុងស្ងួតហើយ ទ្រុឌ |
| លក្ខណៈប្រើប្រាស់ បរិស្ថានជុំវិញ | រូបរាង | សីតុណ្ហភាព ភាពសំនើម | ការផ្លាស់ប្តូរលក្ខណៈជុំវិញ |
| | | | ភាពខុសគ្នារវាងផ្នែកសងខាងនៃរចនាសម្ព័ន្ធ |
| | | | អគ្គិភ័យ |
| | | | កំដៅលើផ្ទៃ |
| | គីមី | ប្រតិកម្មគីមី | ប្រតិកម្មអាស៊ីត/ក្លរ |
| | | | សំនឹកសរសៃដែកដោយកាបូនេតបេតុង |
| | | | សំនឹកដែកដោយក្លរក្នុងបេតុង |
| បន្ទុកមកលើរចនាសម្ព័ន្ធ | លក្ខណៈបន្ទុក | បន្ទុកងាប់/ រយៈពេលវែង | ទទួលបន្ទុកលើសពីការរចនាមក |
| | | បន្ទុករស់/ រយៈពេលខ្លី | ទទួលបន្ទុកលើសពីការរចនាមក |
| | ប្លង់រចនាសម្ព័ន្ធ | | ទំហំ ឬក៏ឆ្អឹងដែកមិនត្រឹមត្រូវ |
| | លក្ខណៈជន្ទល់ | | ការកកមិនស្មើគ្នា |

### 4.3.4 តំណត្រជាក់

នៅពេលដែលចាក់បេតុងខ្នាតធំ ការចាក់នោះត្រូវធ្វើឡើងដោយកើនឡើងតាមកម្រិត។ ប្រសិនជាស្រទាប់មួយនៃបេតុងត្រូវបានចាក់ បន្ទាប់ពីបេតុងដែលបានចាក់មុនក្លាយជារឹង វត្ថុធាតុដែលមិនបន្តនោះហៅថា "តំណត្រជាក់" ដែលជួនកាលកើតឡើងលើផ្ទៃកព្រំដែនរវាងស្រទាប់។ តំណត្រជាក់មិនត្រឹមតែក្លាយជាកត្តាចម្បងក្នុងការធ្វើឲ្យមានភាពខូចខាតលើភាពរឹងមាំនៃរចនាសម្ព័ន្ធតែប៉ុណ្ណោះទេ តែក៏នាំយកមកនូវផលប៉ះពាល់ជាអវិជ្ជមានទៅលើរូបរាងខាងក្រៅ ការការពារទឹក និងភាពធន់ផងដែរ។



**Photo 4.3.3 តំណត្រជាក់**

### (1) មូលហេតុបង្កឲ្យមានតំណត្រជាក់

មូលហេតុចម្បងនៃតំណត្រជាក់ គឺរយៈពេលបេតុងរឹង និងការចាក់លើចន្លោះរវាងស្រទាប់។ កត្តានានាដែលបង្កឡើងមានដូចខាងក្រោម៖

1) កត្តាសម្រាប់រយៈពេលបេតុងរឹង

- ប្រភេទស៊ីម៉ង់ និងសារធាតុលាយ
- ការធ្លាក់ចុះ
- អត្រា ទឹក-ស៊ីម៉ង់
- សីតុណ្ហភាព
- ភាពសំណើម
- មាន ឬក៏គ្មានការរំញ័រឡើងវិញ

2) កត្តាសម្រាប់ការចាក់លើចន្លោះរវាងស្រទាប់

- ដំណាក់កាលនៃការចាក់
- រយៈពេលនៃការចាក់
- រយៈពេលនៃការដឹកជញ្ជូន
- មាន ឬក៏គ្មានរយៈបម្រុងមុននឹងចាក់

## (2) ការបរិយាយស្តង់ដាលម្អិតលើការចាក់លើចន្លោះ

នៅពេលដែលមានស្រទាប់បេតុងពីរត្រូវចាក់ បេតុងនៃស្រទាប់ផ្នែកខាងលើ ត្រូវចាក់មុនស្រទាប់មុនដែលកំពុងតែរឹង។ ម្យ៉ាងទៀតដើម្បីជៀសវាងតំណត្រជាក់ ទុកចន្លោះចាក់ជាអតិបរិមាដូចដែលបានកំណត់ក្នុង **Table 4.3.2** ដោយសារតែក្នុងប្រទេសកម្ពុជាការងារត្រូវធ្វើនៅពេលថ្ងៃ ចន្លោះគោលដៅគួរតែចាក់តិចជាង២ម៉ោង។ ចន្លោះទាំងនេះត្រូវបានកំណត់ជាម៉ោង រវាងរយៈពេលដែលបេតុងត្រូវបានលាយ និងបញ្ចប់ការចាក់នៅស្រទាប់ខាងក្រោម ហើយនិងរយៈពេលដែលបេតុងត្រូវបានចាក់នៅស្រទាប់ខាងលើ ជាមួយនឹងរយៈពេលសម្រាប់ធ្វើការកែសម្រួលជាក់លាក់មួយ។

**Table 4.3.2 ចន្លោះអតិបរិមាក្នុងចាក់ដែលអនុញ្ញាត**

| សីតុណ្ហាភាពជុំវិញ | ចន្លោះអតិបរិមាក្នុងចាក់ដែលអនុញ្ញាត |
|---|---|
| លើសពី25 ℃ | 2.0ម៉ោង |
| ក្រោម25 ℃ | 2.5 ម៉ោង |

## (3) វិធីសាស្រ្តជៀសវាង

វិធីដែលល្អបំផុតដើម្បីជៀសវាងការកើតឡើងនៃតំណត្រជាក់ គឺការរៀបចំផែនការការចាក់ឲ្យបានម៉ត់ចត់បំផុត និងធ្វើការចាក់ទៅតាមផែនការនោះ។ ម្យ៉ាងទៀតការកកើតតំណត្រជាក់ អាចជៀសវាងបានផងដែរ ដោយការប្រើប្រាស់សារធាតុលាយសម្រាប់ពន្យាភាពរឹង។

## 4.4 ការងារបេតុង

### 4.4.1 តម្រូវការសម្រាប់វត្ថុធាតុបេតុងថ្មី

(1) ជម្រៅគួរតែ 80mm

ការធ្វើបេតុងតែងតែកំណត់ដោយភាពងាយស្រួល ដែលបេតុងថ្មីអាចខូចទ្រង់ទ្រាយ និងធន់ទៅនឹងការបែងចែកនៃវត្ថុធាតុ។ សម្រាប់បេតុងទូទៅ វាអាចបង្កើតពីជម្រៅ និងទំហំអតិបរិមានៃគ្រួសដុំ។

(2) ឯកតានៃស៊ីម៉ង់បេតុង ត្រូវកំណត់ពីឯកតានៃសមាសធាតុទឹក និងអត្រានៃទឹក-ស៊ីម៉ង់។ សម្រាប់ឯកតាស៊ីម៉ង់បេតុងជាអប្បបរមាវិញ តម្លៃក្នុង **Table 4.3.1** ត្រូវបានធ្វើឡើងជាទូទៅ។

**Fig. 4.3.1 ឯកតាសមាសធាតុស៊ីម៉ង់អប្បបរមា(kg/m³)**

| ប្រភេទសមាជិកសមាសធាតុ | | ឯកតាសមាសធាតុស៊ីម៉ង់អប្បបរមា |
|---|---|---|
| សមាជិកជួយពង្រឹងបេតុង | | 230 |
| សមាជិកបេតុងដែលបានសង្កត់មុន | វិធីសាស្ត្រសង្កត់មុន | 350 |
| | វិធីសាស្ត្រសង្កត់ក្រោយ | 300 |

ឯកតាសមាសធាតុស៊ីម៉ង់ ត្រូវកំណត់ដោយឯកតាសមាសធាតុទឹក និងអត្រាទឹក- ស៊ីម៉ង់។ ក្នុងវិធីសាស្ត្រសង្កត់មុន កម្លាំងតភ្ជាប់រវាងបេតុង និងសរសៃ PC ត្រូវធានាឲ្យបានគ្រប់គ្រាន់។ ដូចនេះហើយ ឯកតាសមាសធាតុស៊ីម៉ង់អប្បបរមាក្នុងវិធីសាស្ត្រសង្កត់មុន គឺបានដាក់ឲ្យធំជាងក្នុងវិធីសាស្ត្រសង្កត់នៅពេលក្រោយ។ ដោយសារតែមានហានិភ័យនៃសមាសធាតុទឹកទំហំធំមានផលប៉ះពាល់អន្តរាយទៅលើរចនាសម្ព័ន្ធ ដូចជាស្នាមប្រេះ កើតឡើងដោយសារតែសំពាធកំដៅ និងទ្រុឌពេលដែលស្ងួត ការត្រួតពិនិត្យត្រូវបានធ្វើឡើងចំពោះវិធីសាស្ត្រសាងសង់ និងវិធីសាស្ត្រក្នុងការកែតម្រូវ នៅពេលដែលឯកតាសមាសធាតុស៊ីម៉ង់ខ្ពស់។

(3) អត្រាខ្សាច់ត្រូវបានកំណត់ ដើម្បីធ្វើឲ្យឯកតាសមាសធាតុទឹកកាត់បន្ថយ ក្នុងកម្រិតមួយដែលអាចធ្វើការងារបានស្រួល។

(4) ទំហំអតិបរិមានៃគ្រួសដុំគឺ ៤០ ម.ល ឬក៏តិចជាងនេះ ហើយមិនត្រូវធំជាង ១/៥ នៃទំហំអប្បបរមារបស់សមាជិក និងមិនធំជាង 3/4 នៃ ចម្ងាយអប្បបរមាច្បាស់លាស់នៃឆ្អឹងដែក។ ទំហំគ្រួសដុំជាអតិបរិមាផ្អែកទៅលើចំនួន និងការរៀបចំដែក ក៏ប៉ុន្តែ គេចង់បានវាក្នុង 20 ឬក៏ 25mm។

### 4.4.2 ការរក្សាទុក

វត្ថុធាតុត្រូវរក្សាទុក ដើម្បីឲ្យគុណភាពរបស់ពួកវាមិនផ្លាស់ប្តូរ។ យើងចង់រក្សាវត្ថុធាតុដោយផ្តោតទៅលើបញ្ហាដូចខាងក្រោម ដើម្បីរក្សាគុណភាពរបស់ពួកវា។

1)ការរក្សាទុកដែក

ឆ្អឹងដែក និងដែករចនាសម្ព័ន្ធ ត្រូវរក្សាក្នុងចន្លោះដែលសមរម្យ និងទុកក្នុងឃ្លាំង ឬក៏ ប្រសិនបើទុកនៅខាងក្រៅ ត្រូវគ្របឲ្យបានសមរម្យ ជៀសវាងការដាក់ទៅលើដីផ្ទាល់។

2)ការរក្សាទុកស៊ីម៉ង់

នៅពេលដែលស៊ីម៉ង់បានរក្សាទុកក្នុងរយៈពេលយូរ ស៊ីម៉ង់នោះត្រូវធ្វើការសាកល្បង ដើម្បីធានាគុណភាពរបស់វា មុននឹងធ្វើការប្រើប្រាស់។

នៅពេលដែលសីតុណ្ហភាពស៊ីម៉ង់ខ្ពស់ពេក ត្រូវធ្វើឲ្យសីតុណ្ហភាពស៊ីម៉ង់ធ្លាក់ចុះ មុននឹងយកមកប្រើប្រាស់។

ប្រសិនបើបាវស៊ីម៉ង់ត្រូវបានរក្សាទុក អស់រយៈពេលយូរ ឬក៏ក្នុងអំឡុងពេលមានសំណើមខ្ពស់ វាជាការអនុវត្តន៍ល្អ ក្នុងការចាតវិធានការការពារអាកាសធាតុ ដូចជាការប្រើប្រាស់បាវរៀបជាមួយនឹងផ្លាស្ទិចការពារសំណើម។ ប្រសិនជាបាវស៊ីម៉ង់ត្រូវបានដាក់គរគ្នា ពេលដែលរក្សាទុក ស៊ីម៉ង់ដែលនៅក្នុងបាវក្រោមគេអាចកក។ កម្រិតដែលផ្តល់ជាអនុសាសន៍សម្រាប់ចំនួនស្រទាប់គរបាវស៊ីម៉ង់ ប្រហែលជា១៣ ស្រទាប់។



**Photo 4.4.1 កន្លែងរក្សាទុកសម្ភារ**

### 4.4.3 ការងារបេតុង

(1) ទូទៅ

ក្នុងការធ្វើបេតុង ផែនការគួរតែបង្កើតមុន ដោយគិតគូរពីវិធីសាស្ត្រដឹកជញ្ជូនបេតុង ផ្លូវដឹកជញ្ជូន ការដ្ឋានទុកដាក់ វិធីសាស្ត្រការចាក់ ដំណាក់កាលការចាក់ ចំនួននៃការចាក់ម្តង វិធីសាស្ត្រក្នុងការកែតម្រូវ និងវិធីសាស្ត្រក្នុងការកែកែប្រែតំណសំណង់ ដើម្បីធានាបាននូវគុណភាពដែលបានដាក់ចេញ។

(2) ការដឹកជញ្ជូន

បេតុងគួរតែដឹកជញ្ជូន និងទុកដាក់ដោយប្រើប្រាស់វិធីសាស្ត្រសាកសម ដើម្បីជៀសវាងការកើតឡើងនៃការបែកនៃវត្ថុធាតុ ។

ពេលដែលប្រើប្រាស់ម៉ាស៊ីនបូមបេតុង ប្រភេទម៉ាស៊ីនបូមបេតុងសាកសមត្រូវបានជ្រើសរើសដោយគិតពីវិធីសាស្ត្រក្នុងការចាក់បេតុង។ ក្នុងការដាក់បំពង់បាញ់ ត្រូវធានាថាបំពង់បាញ់មិនមានភ្ជាប់មកជាមួយនឹងការរំញ័រ ឬក៏ការបំបែកដែលមានផលប៉ះពាល់ឆ្អឹងដែក ពុម្ព ឬក៏ជន្ទល់ឡើយ។ បំពង់ដែក គួរតែដាក់ផ្តេក ឬក៏បាញ់ឡើងលើ។ ដោយសារតែបំពង់បាញ់ទៅម៉ាស៊ីនបូម មានចលនាពេលដែលបេតុងកំពុងតែត្រូវបានបូម វាមិនគួរដាក់ចំឆ្អឹងដែក ពុម្ព ឬក៏ របស់ស្រដៀងនេះនោះទេ ប៉ុន្តែគួរតែដាក់លើជន្ទល់។

(3) ការចាក់

1) ការចាក់បេតុងជាទូទៅមិនត្រូវធ្វើឡើងពេលដែលមានភ្លៀង ឬក៏ខ្យល់ខ្លាំងនោះទេ។

2) មុននឹងចាប់ផ្តើមធ្វើការចាក់បេតុង កន្លែងដែលត្រូវចាក់ និងពុម្ព ត្រូវសម្អាតដើម្បីជៀសវាងពីបញ្ហាផ្សេងៗដែលអាចជៀបចូលបេតុង។ ផ្នែកដែលអាចស្រូបយកសំណើមរបស់បេតុង ត្រូវចាក់ក្នុងលក្ខខណ្ឌសើមជាមុន។

3) រយៈពេលពីការលាយរហូតដល់បញ្ចាប់ការចាក់

តាមស្តង់ដា រយៈពេលពីការបញ្ចប់ការលាយ ទៅការបញ្ចប់ការចាក់ គួរតែ២ ម៉ោង ឬក៏តិចជាងនេះ ឬក៏ ១.៥ ម៉ោង ឬក៏តិចជាងនេះ នៅពេលខ្យល់ខាងក្រៅមានសីតុណ្ហភាព ២៥ អង្សារសេ ឬក៏តិចជាងនេះ ឬក៏ ខ្ពស់ជាង ២៥ អង្សារសេ។

4) ប្រសិនជាបេតុងត្រូវចាក់ជាពីរ ឬក៏ច្រើនស្រទាប់ ការចាក់គួរធ្វើឡើង ដើម្បីធ្វើឲ្យស្រទាប់ពីខាងលើភ្ជាប់ស៊ីគ្នានឹងស្រទាប់ខាងក្រោម។ ទីតាំងនៃ កន្លែងរឹង ផ្ទុកចំនុះបេតុង ចន្លោះពេលសម្រាប់ចាក់ នីមួយៗ.ល. ត្រូវកំណត់

ដើម្បីកុំឲ្យមានលទ្ធផលតំណត្រជាក់។ ពាក្យថា ចន្លោះពេលសម្រាប់ចាក់ គឺជារយៈពេលបន្ទាប់ពីបានបញ្ចប់ការចាក់ និងការបង្ហាប់ស្រទាប់ខាងក្រោមនៃបេតុង រហូតដល់ស្រទាប់ខាងលើនៃបេតុងត្រូវបានចាក់បន្ទាប់ពីរយៈពេលរង់ចាំបន្តិច។ ស្តង់ដាចន្លោះពេលសម្រាប់ចាក់ ត្រូវបានបង្ហាញក្នុង **Table 4.3.2**។

(4)ការបង្ហាប់

1) ក្នុងគោលការណ៍ ម៉ាស៊ីនរំញ័រខាងក្នុង គួរតែប្រើប្រាស់សម្រាប់ធ្វើការបង្ហាប់បេតុង។ ម៉ាស៊ីនរំញ័រពុម្ព អាចប្រើប្រាស់បានសម្រាប់រចនាសម្ព័ន្ធដែលបានជញ្ជាំងស្តើង ដែលការប្រើប្រាស់ម៉ាស៊ីនរំញ័រខាងក្នុងមានភាពលំបាក។

2) ក្នុងការធ្វើការបង្ហាប់បេតុង ត្រូវធានាបានថាបេតុងត្រូវបានចាក់ពេញឆ្អឹងដែក និងគ្រប់ជ្រុងនៃពុម្ព។

3) ការតំឡើងរន្ធ និងវិធីសាស្ត្រចាក់បេតុង ត្រូវកំណត់ ដើម្បីកុំឲ្យកម្ពស់នៃការចាក់ លើសពីតម្លៃដែលបានរៀបចំទុក។

4) បេតុងដែលនៅជិតគ្នាទៅ បន្ទះពុម្ព ត្រូវបង្ហាប់ជុំវិញបន្ទះពុម្ពឲ្យបានត្រឹមត្រូវ ដើម្បីធានាបានថាផ្ទៃបេតុងចុងក្រោយគឺរាបតាមតែអាចធ្វើទៅបាន។

5) ក្នុងអំឡុងពេលបង្ហាប់ប្រើប្រាស់ម៉ាស៊ីនរំញ័រ ម៉ាស៊ីនរំញ័រត្រូវបញ្ចូលក្នុងជម្រៅប្រមាណ 10cm ទៅក្នុងស្រទាប់ខាងក្រោមនៃបេតុង។

6) ចន្លោះមិនគួរធំជាងមួយអង្កត់ផ្ចិតក្នុងជួរដែលម៉ាស៊ីនរំញ័របានប្រសិទ្ធិភាពទេ ដែលជាធម្មតា 50cm ឬក៏តិចជាងនេះសម្រាប់បេតុងជាមួយនឹងកម្រិតរាវ និងកម្រិតរំអិលធម្មតា។

7) កន្លែងនៃចន្លោះម៉ាស៊ីនរំញ័រ និងពេលវេលារំញ័រ ក្នុងទីតាំងនីមួយ ត្រូវកំណត់ ដើម្បីឲ្យបេតុងអាចបង្ហាប់បានគ្រប់គ្រាន់។ ម៉ាស៊ីនរំញ័រខាងក្នុងត្រូវដកចេញម្តងបន្តិច ដើម្បីកុំឲ្យមានប្រហោងក្នុងបេតុង។ តាមបទពិសោធន៍ពេលវេលារំញ័រគឺប្រហែលជាពី 5 ទៅ 15 វិនាទី។ ការដកម៉ាស៊ីនរំញ័រម្តងបន្តិចពិតជាមានសារៈសំខាន់ណាស់ដើម្បីធ្វើឲ្យប្រាកដថាមិនមានប្រហោងក្នុងបេតុង។

8) ពេលវេលាសម្រាប់ការធ្វើរំញ័រឡើងវិញ គួរតែយឺតតាមតែអាចធ្វើទៅបានតាមវិសាលភាពមួយដែលអាចធ្វើការបង្ហាប់បេតុងបាន ហើយមិនមានផលប៉ះពាល់អាក្រក់ណាមួយ ដូចជាស្នាមប្រេះលើបេតុងជាដើម។

9) ម៉ាស៊ីនរំញ័រមិនត្រូវប្រើប្រាស់សម្រាប់ធ្វើចលនាពីខាងនោះទេ ដែលវាអាចបង្កឲ្យមានការបែក។



**Photo 4.4.2 បង្ហាប់**

(5) ការថែទាំ



**Photo 4.4.3 ថែទាំ**

1) បេតុងត្រូវធ្វើការថែទាំ ដើម្បីកុំឲ្យវាផ្អែកទៅតាមផលប៉ះពាល់នៃ ការស្ងួត សីតុណ្ហភាព ឬក៏ការផ្លាស់ប្តូរសីតុណ្ហភាពភ្លាមៗ បន្ទាប់បានចាក់រួច។

2) បេតុងត្រូវធ្វើការថែទាំ ដើម្បីកុំឲ្យវាផ្អែកទៅតាមផលប៉ះពាល់ពីការរំញ័រ ផលប៉ះពាល់ ឬក៏ស្រដៀងនេះ ពេលដែលវាកំពុងតែរឹង។

3) វិធីសាស្ត្រកែតម្រូវជាទូទៅគឺជាការកែតម្រូវដោយភាពសើម។ ពេលដែលស៊ីម៉ង Portland ធម្មតាត្រូវបានប្រើ

ប្រាស់ បេតុងត្រូវកែតម្រូវយ៉ាងហោចណាស់៥ថ្ងៃ បន្ទាប់ពីបានចាក់ ហើយប្រសិនបើស៊ីម៉ង់ Portland ដែលមានសមត្ថភាពខ្ពស់ ត្រូវបានប្រើប្រាស់វិញ បេតុងត្រូវកែតម្រូវយ៉ាងហោចណាស់ ៣ថ្ងៃ បន្ទាប់ពីបានចាក់។ ទឹកសមុទ្រមិនត្រូវប្រើប្រាស់ធ្វើជាទឹកសម្រាប់កែតម្រូវនោះទេ។

(6) តំណសំណង់

1) តំណសំណង់ត្រូវ បង្កើតនៅទីតាំងនៃកម្លាំងកាត់ និងកាត់កែងតូចមួយ នៃសកម្មភាពកម្លាំងសង្កត់នៅលើសមាជិក។

2) សម្រាប់តំណសំណង់ ត្រូវធ្វើការគិតគូរ ដើម្បីកុំឲ្យស្នាមប្រេះដែលបណ្ដាលមកពីការរងសំពាធពីកំដៅ និងការទ្រុឌចុះពេលស្ងួត កើតឡើង។ នៅតំណសំណង់ មានហានិភ័យនៃស្នាមប្រេះ បង្កដោយការរងសំពាធពីកំដៅដោយសារតែកំដៅទឹក ការរងសំពាធពីកំដៅដោយសារតែផលប៉ះពាល់ពីសីតុណ្ហភាពខ្យល់នៅជុំវិញ ការទ្រុឌចុះពេលស្ងួត និងការបង្កផ្សេងៗទៀត។ ដូចនេះហើយការងារសាងសង់ត្រូវធ្វើឡើងក្នុងឥរិយាបទមួយដែលកាត់បន្ថយភាពខុសគ្នានៃសីតុណ្ហភាពរវាងបេតុងថ្មី និងបេតុងដែលបានចាក់រួច។ នៅក្បែរតំណសំណង់ វាមានភាពចាំបាច់ក្នុងការដាក់ឈ្នាន់កែបសេះ ដែកកាត់ទទឹង និងឆ្អឹងដែកផ្សេងៗ ឲ្យបានក្រាស់ ជាងផ្នែកផ្សេងៗ ឬក៏ចាត់វិធានការផ្សេងទៀត។

3) នៅតំណសំណង់ ផ្ទៃបេតុង គួរតែមិនមានស្នាមទឹក គ្រួសរបូត ឬក៏ស្រដៀងនេះ ហើយអនុញ្ញាតឲ្យស្រូបទឹកបានល្អ មុននឹងចាក់បេតុងថ្មី។ ទឹកដែលនៅសល់លើបេតុងដែលបានចាក់រួច ត្រូវសម្អាតចេញមុននឹងចាក់បេតុងថ្មី។

4) សម្រាប់រចនាសម្ព័ន្ធដែលជួបនឹងបរិស្ថានដែលមានជាតិអំបិល ដូចជាមាត់សមុទ្រ វាត្រូវបានផ្ដល់ដំបូន្មានឲ្យកាត់បន្ថយចំនួនតំណសំណង់ ហើយតំណឈរគួរតែបំបែរចេញឲ្យឆ្ងាយតាមតែអាចធ្វើទៅបាន។

5) នៅពេលដែលបេតុងត្រូវបានចាក់ច្រើនដងក្នុងស្រទាប់ច្រើនជាន់ ភាពចូលគ្នាគួរតែធានាបាននៅផ្ទៃស្រទាប់រវាងស្រទាប់ខាងលើ និងខាងក្រោមនៃបេតុង ហើយស្នាមប្រេះ ឬក៏តំណត្រជាក់ជាមួយនឹងផលប៉ះពាល់មិនល្អទៅលើភាពធន់ នឹងមិនត្រូវកើតឡើងនោះទេ។ នៅពេលដែលបេតុងនៅខាងក្រោមចាប់ផ្ដើមរឹង វាមានហានិភ័យក្នុងការកកើតឡើងនៃតំណត្រជាក់ នៅពេលដែលចាក់បេតុងខាងលើ ប្រសិនបើគ្មានការគិតគូរជាមុន។ ដើម្បីជៀសវាងបញ្ហានេះ វាមានសារៈសំខាន់ក្នុងកំណត់ និងគ្រប់គ្រងចន្លោះចាក់ ដោយគិតពីប្រភេទនៃផលប៉ះពាល់ និងគុណភាពបេតុង រយៈពេលចាប់តាំងពីចាប់ផ្ដើមច្របាច់បេតុង រហូតដាក់ការបញ្ចប់ការចាក់ សីតុណ្ហភាពបេតុង វិធីសាស្ត្របង្ហាប់ និងកត្តាផ្សេងៗទៀត។

### 4.4.4 ការងារ និងការដាក់ឆ្អឹងដែក

(1) ឆ្អឹងដែលត្រូវរៀបឲ្យបានតឹងដោយប្រើប្រាស់ចន្លោះធ្វើពីបេតុង ឬក៏បាយអរដែលមានគុណភាពស្មើ ឬក៏ខ្ពស់ជាងតួបេតុង ដើម្បីកុំឲ្យបង្កមានការបែកចេញពីទីតាំងក្នុងអំឡុងពេលចាក់បេតុង។

(2) ឆ្អឹងដែកត្រូវពត់ក្នុងសីតុណ្ហភាពធម្មតា ហើយការងារពត់ត្រូវធ្វើឡើងដោយប្រើប្រាស់ម៉ាស៊ីនពត់ក្នុងឥរិយាបទមួយដែលមិនបង្កឲ្យមានការផ្លាស់ប្តូរទៅលើគុណភាពវត្ថុធាតុ។

(3) នៅពេលរៀបឆ្អឹងដែក ច្រេះ ឬក៏បញ្ហាផ្សេងៗដែលអាចប៉ះពាល់ដល់ការភ្ជាប់ជាមួយនឹងបេតុង ត្រូវសម្អាតចេញ។ បញ្ហារួមមាន ច្រេះ ភក់ ប្រេង ថ្នាំលាប ឬក៏ផ្សេងៗទៀតដែលប៉ះពាល់រវាងបេតុង និងឆ្អឹងដែក។ មិនត្រឹមតែបញ្ហាទាំងនេះត្រូវសម្អាត ក្នុងការរៀបឆ្អឹងដែកប៉ុណ្ណោះទេ ប៉ុន្តែវាគួរតែធានាបានថាបញ្ហាទាំងនេះមិនមានទៅលើឆ្អឹងដែក ក្នុងអំឡុងពេលទុកដាក់ ឬក៏ធ្វើការប្រើប្រាស់។

(4) នៅពេលដែលតំណជាន់គ្នាត្រូវបានប្រើប្រាស់ ប្រវែងដែលកំណត់ ត្រូវដាក់ឲ្យជាន់គ្នា និងភ្ជាប់ឲ្យបានតឹងដោយដែកលួសទំហំ 0.9mm ឬក៏ ធំជាងនេះក្នុងអង្កត់ផ្ចិត។

(5) ឆ្អឹងដែកលយចេញពីរចនាសម្ព័ន្ធក្នុងស្ថានភាពងាយរងគ្រោះសម្រាប់ការពង្រីកនាពេលអនាគត ត្រូវការពារពីភាពខូចខាត សំនឹង និងបញ្ហាស្រដៀងនេះ។ នៅពេលដែលឆ្អឹងដែកទុកនៅខាងក្រៅអស់រយៈពេលយូរសម្រាប់ការពង្រីកនាពេលអនាគត ឆ្អឹងដែកនោះត្រូវបៀកដោយស៊ីម៉ង់ ឬក៏ការពារដោយគ្របផ្លាស្ទិច ឬក៏ម្យ៉ាងទៀតធ្វើការកែតម្រូវដើម្បីការពារវាពីភាពខូចខាត ឬក៏ផលប៉ះពាល់ដែលបង្កដោយសំនឹក។

## 4.5 ការសាកល្បងបញ្ជាក់ពីគុណភាពបេតុង

### 4.5.1 ការសាកល្បងការធ្លាក់ចុះ

ការសាកល្បងការធ្លាក់ចុះត្រូវបានប្រើប្រាស់ដើម្បីយល់ដឹងពីដំណើរការនៃបេតុងថ្មី និងរបៀបដែលងាយស្រួលបំផុតក្នុងការយល់ដឹងពីគុណភាពបេតុង។ ការសាកល្បងការធ្លាក់ចុះនៃបេតុងត្រូវបានប្រើប្រាស់សម្រាប់ធ្វើការវាស់វែងគុណភាពគុណភាពបេតុង។ ការសាកល្បងនេះគឺជាការសាកល្បងអះអាងពីវិធានការដែលបេតុងថ្មីអាចដំណើរការបាន។ លម្អិតជាងនេះ វាវាស់វែងពីភាពស៊ីគ្នារវាងក្រុម។ ការសាកល្បងនេះមានប្រជាប្រិយភាពដោយសារតែការប្រើប្រាស់ឧបករណ៍មានភាពងាយស្រួល ហើយដំណាក់កាលសាមញ្ញ។

ការធ្លាក់ចុះធំមានន័យថាដំណើរការការងារខ្ពស់។ ប៉ុន្តែមិនសូវល្អសម្រាប់ភាពធន់នៃបេតុង។ ហើយការធ្លាក់ចុះបេតុងកាន់តែធំ កាន់តែមានភាពងាយស្រួលក្នុងការធ្វើបំណែងចែកវត្ថុធាតុ ដែលមានទឹកច្រើន ហើយការធ្វើបំណែងចែកមានភាពងាយស្រួល និងគុណភាពបេតុងបន្ទាប់ពីបុកចុះ គឺងាយនឹងក្លាយជាមិនស្មើសាច់ ហើយការទ្រុឌបន្ទាប់ពីស្ងួត ក៏ធំផងដែរ។ ដូចនេះហើយ វាមានសារៈសំខាន់ក្នុងការកាត់បន្ថយការធ្លាក់ចុះដែលរួមមានទឹកក្នុងកម្រិតនៃដំណើរការចាក់។




**Photo 4.5.1 ធ្វើតេស្តការធ្លាក់ចុះ**

វិធីសាស្ត្រសាកល្បងការធ្លាក់ចុះមានដូចខាងក្រោម (**Fig. 4.5.1**)

① ឧបករណ៍សាកល្បងហៅថាសាជីការធ្លាក់ចុះបានរៀបចំរួចរាល់។ សាជីដែកការធ្លាក់ចុះត្រូវបានដាក់លើទ្រនាប់ដែលរឹង មិនជៀបទឹក និងស្មើ។

② បំពេញសាជីការធ្លាក់ចុះជាមួយនឹងបេតុងថ្មីក្នុង៣ជំហាន ស្រទាប់បីស្មើគ្នា។

③ ក្នុងដំណាក់កាលនីមួយៗ បង្ហាប់២៥ដង ដោយដំបង។ ស្រទាប់នីមួយៗត្រូវមូល ២៥ ដង ដើម្បីធានាការបង្ហាប់បានល្អ។

④ បញ្ចាប់ផ្ទៃកខាងលើឲ្យបានរាប ហើយដកសាជីការធ្លាក់ចុះចេញដោយបញ្ឈរ និងយឺតៗ។ ហើយ ការធ្លាក់ចុះត្រូវបានវាស់វែង។ ស្រទាប់ទីបីត្រូវបញ្ចាប់ដោយមានភាពស្មើគ្នាជាមួយនឹងផ្ទៃកខាងលើនៃសាជី។ សាជីត្រូវដកចេញដោយប្រុងប្រយ័ត្ន ដោយទុកពំនូកបេតុងដែលរឹង ឬក៏ "ការធ្លាក់ចុះ" បន្តិច។ ភាពខុសគ្នានៃកម្រិតរវាងកម្ពស់នៃសាជីការធ្លាក់ចុះ និងចំណុចដែលខ្ពស់ជាងគេនៃបេតុងដែលធ្លាក់ចុះ ត្រូវបានវាស់វែង។ ភាពខុសគ្នាក្នុងកម្ពស់នេះត្រូវគិតជា ម.លី គឺជាការធ្លាក់ចុះនៃបេតុង។




**Fig. 4.5.1** ជំហានក្នុងការត្រួតការធ្លាក់ចុះ

## 4.5.2 ការសាកល្បងសមាសធាតុខ្យល់



**Photo 4.5.2 ត្រួសកំរិតខ្យល់**

ការត្រួសកំរិតខ្យល់គឺវាស់វែងសមាសធាតុខ្យល់មាននៅក្នុងបេតុង។

ការសាកល្បងសម្រាប់សមាសធាតុខ្យល់នៃបេតុងដែលទើបនឹងលាយថ្មីៗ ដោយវិធីសាស្ត្រសំពាធត្រូវបានផ្អែកលើច្បាប់ Boyle ដែលចែងថាទំហំដែលប្រើប្រាស់ដោយខ្យល់គឺមានសមាមាត្រទៅនឹងការសំពាធដែលបានប្រើប្រាស់។ កុងទ័រដែលបានបង្ហាញក្នុងរូបថតខាងលើ ចន្លោះខ្យល់ចែកដាច់ ត្រូវបានភ្ជាប់តាមរយៈក្បាលវ៉ាល់ ដើម្បីធ្វើការសាកល្បងការផ្តុំ ដែលចាក់បំពេញដោយបេតុង។ ជាមួយក្បាលវ៉ាល់បានបិទជិត ចន្លោះចែកដាច់ដោយឡែកត្រូវបានរងសំពាធ ដើម្បីធ្វើការកំណត់ការសំពាធប្រតិបត្តិការណ៍។ នៅពេលដែលក្បាលវ៉ាល់បើក ខ្យល់រីកទៅក្នុងចន្លោះសាកល្បង ហើយសំពាធធ្លាក់ចុះក្នុងសមាមាត្រទៅតាមខ្យល់នៅក្នុងគំរូបេតុង។

នៅពេលលាយបេតុង ខ្យល់តិចតួចត្រូវបានដាក់ចូលក្នុងបេតុង។ ចំនុះខ្យល់កាន់តែធំ ការដំណើរការបេតុងកាន់តែល្អ។ ក៏ប៉ុន្តែ ប្រសិនបើខ្យល់ត្រូវបានដាក់ចូលច្រើនពេក កម្លាំងសំពាធត្រូវកាត់បន្ថយ។

ដូចនេះហើយគួរតែបង្កើត សមាសធាតុខ្យល់សមរម្យមួយ។

វិធីសាស្ត្រក្នុងការសាកល្បងសមាសធាតុខ្យល់មានដូចខាងក្រោម **(Fig. 4.5.2)**

① ឧបករណ៍សាកល្បងត្រូវបានដាក់ឲ្យរាបស្មើ

② ឧបករណ៍សាកល្បងត្រូវបានបំពេញដោយបេតុងថ្មី ក្នុង 3 ជំហាន ស្រទាប់បីស្មើគ្នាៗ។

③ ក្នុងជំហាននីមួយត្រូវបង្ហាប់ 25 ដងដោយដំបង។

④ ផ្នែកចំហៀងនៃឧបករណ៍សាកល្បងត្រូវវាយថ្នមៗជាមួយនឹងញញួរ

⑤ ធ្វើការគ្រប ហើយខាងក្នុងនៃឧបករណ៍សាកល្បងត្រូវបានធ្វើទៅជាការម៉ាស៊ីនស្រូប។

⑥ សមាសធាតុខ្យល់ត្រូវបានវាស់វែង។

⑦ ទំងន់នៃឧបករណ៍សាកល្បងត្រូវបានវាស់វែង។

⑧ ឯកតាសមាសធាតុទឹក អាចគណនាបានដោយសមាសធាតុទឹក និងទំងន់គំរូ។




**Fig. 4.5.2 ជំហាននីមួយៗក្នុងការត្តេសកំរិតខ្យល់**

### 4.5.3 ការសាកល្បងកម្លាំងសំពាធ

វិធីសាស្ត្រសាកល្បងកម្លាំងសំពាធនៃបេតុងរឹងនេះ។ ពួកយើងបញ្ជាក់ថាកម្លាំងបេតុង ចាក់ក្នុងការដ្ឋានលើសពីឧបករណ៍ដែលបានកំណត់។ វិធីសាស្ត្រសាកល្បងកម្លាំងសំពាធនៃបេតុងរឹងនេះ ដើម្បីបញ្ជាក់ថាបេតុងមានកម្លាំងដែលបានកំណត់មក ឬក៏មិនមាន។

ពួកយើងសាកល្បងបំណែកចំនួនបី ហើយកម្លាំងសំពាធគឺមធ្យម។ កម្លាំងសំពាធមធ្យមនៃគំរូទាំងបី ត្រូវបានចាត់ទុកជាលទ្ធផល។




**Photo 4.5.3 ការសាកល្បងកម្លាំងសំពាធ**

(1) វិធីសាស្ត្រធ្វើគំរូ (**Photo 4.5.4**)

1) ក្នុងករណីគំរូបានមកពីខ្នូរប្រដាប់ខូង

ដើម្បីឲ្យស៊ីម៉ង់ថ្មីស្មើសាច់គ្នា គំរូគួរតែយកឲ្យស្មើបន្ទាប់ពីការកូរក្នុងល្បឿនខ្ពស់ និងដកបេតុងចំនួន 50 ឬក៏ 100 លីត្រដំបូងចេញ។

2) ក្នុងករណីគំរូបានមកពីការចាក់បេតុង

គំរូគួរតែយកមកពីកន្លែងបីដែលបានចាក់បេតុង។



**(a) ចេញពីម៉ាស៊ីនក្រលុក**



**(b) ចេញពីបំពុងបេតុង**

**Photo 4.5.4 វិធីសាស្ត្រអនុវត្តន៍**

(2) ការធ្វើប៉ាន់

*ប៉ាន់បីគួរតែធ្វើក្នុង 150$m^3$ – 300$m^3$ ម្តងសម្រាប់ការចាក់បេតុង។

* ប៉ាន់គួរតែធ្វើជារាងស៊ីឡាំងជាមួយនឹងអង្កត់ផ្ចិត 100mm ឬក៏ច្រើនជាងនេះ ឬក៏៣ដងនៃគ្រួសជាអតិបរមា និង កម្ពស់ខ្ពស់ជាងនេះ ឬក៏ ២ដងនៃអង្កត់ផ្ចិត (ឧទាហរណ៍ φ100×200 mm) (**Photo 4.5.5**)

* ចាក់បំពេញពុម្ពជាមួយនឹងបេតុងថ្មីក្នុងស្រទាប់២ស្មើគ្នា ឬក៏ច្រើនជាងនេះ គឺត្រូវវាយ១ ដង ក្នុង១០ ដង ដើម្បី ធានាការបង្ហាប់។

* ពុម្ពគួរតែដកចេញបន្ទាប់ពី ១៦ ទៅ ៧២ ម៉ោង។ ប៉ាន់គួរតែដាក់ឲ្យឆ្ងាយពីការប៉ះពាល់ ឬក៏ការរំញ័រ និងការពារ មិនឲ្យស្ងួតក្នុងអំឡុងពេលចាក់ពុម្ព។

* បន្ទាប់មក ប៉ាន់គួរតែរក្សាក្នុងធុងទឹកដែលមានសីតុណ្ហភាពស្មើ ហើយការសាកល្បងសំពាធ នឹងត្រូវឡើងក្នុង ថ្ងៃទី ២៨។




**Photo 4.5.5 បំពង់ស៊ីឡាំង**

## 4.5.4 ការធ្វើតេស្តរកអ៊ីយ៉ុងក្លរ

នៅពេលដែលមានអ៊ីយ៉ុងក្លរក្នុងបេតុង ឆ្អឹងដែកងាយនឹងច្រេះចាប់។ ម្យ៉ាងទៀតវត្តមាននៃសូដ្យូមក្លរក្នុងបេតុង អាចបង្កឲ្យមានប្រតិកម្ម អាកាឡាំង ស៊ីលីកា។ ដើម្បីជៀសវាងបញ្ហាដែលទាក់ទងនឹងក្លរចំនួនសរុបនៃសមាសធាតុ អ៊ីយ៉ុងក្លរក្នុងបេតុងគួរតែតិចជាង 0.3kg/$m^3$ ក្នុងរូបមន្ត។

វិធីសាស្ត្រសាកល្បងដើម្បីវាស់វែងទំហំនៃបេតុង អ៊ីយ៉ុងក្លររួមមាន ការសាកល្បងចៀក (តេស្តQuan Tab) ការសាកល្បងដោយម៉ាស៊ីន និងវិធីសាស្ត្រការវិភាគស្ងួត ដោយប្រើប្រាស់ម្សៅបេតុង ខួងជ្រៅពីគំរូចម្បង។ ថ្មីៗនេះ ឧបករណ៍ 'Electron Probe Micro Analyzer' (EPMA) អាចវាស់វែងសមាសធាតុ ក្លរ បានត្រឹមត្រូវ និងឆាប់រហ័ស។





**Photo 4.5.6 តេស្តរកសមាសភាពអ៊ីយ៉ុងក្លរ**